# ពុទ្ធប្បវត្តិ

## ទូរេនិទាន

ភាគ ១

ធម្មវិនយោ លោកេ បវត្តតុ

*បោះពុម្ពលើកទី ៦*

សម្រាប់សាលាធម្មវិន័យ

ថ្នាក់ត្រី

# ពុទ្ធប្បវត្តិ

## ទូរេនិទាន

### ភាគ ១

បោះពុម្ពលើកទី ៦

សម្រាប់សាលាធម្មវិន័យ

ថ្នាក់ត្រី

# អារម្ភកថា

សៀវភៅនេះ ឈ្មោះ ពុទ្ធប្បវត្តិ តំណាលពីប្រវត្តិ គឺដំណើរដែលប្រព្រឹត្តទៅ ឬពីរឿងរ៉ាវ នៃព្រះពុទ្ធ ដរាបដល់បរិនិព្វានជាទីបំផុត ។ ពុទ្ធប្បវត្តិនេះ យើងជាគណៈកម្មការធម្មវិន័យបានរើសស្រង់សេចក្តីពីគម្ពីរឯកនិបាតជាតកដ្ឋៈ ពីគម្ពីរអដ្ឋកថាធម្មចក្កប្បវត្តនសូត្រៈ ពីគម្ពីរជិនមហានិទានខ្លះ ដែលមានសេចក្តីផ្សេងគ្នាដោយអន្លើ ៗ មករៀបរៀងរំលែកចែកជា ៣ និទាន គឺទី ១ ហៅថា ទូរេនិទាន ពណ៌នាអំពីព្រះពុទ្ធនៃយើងកាលនៅជាពោធិសត្វឈ្មោះ សុមេធបណ្ឌិត ដែលកើតក្នុងត្រកូលព្រាហ្មណ៍ ដរាបដល់មកកើតជាសន្តុសិតទេវបុត្រ នាឋានតុសិតទេវលោក ។ ទី ២ ហៅថា អវិទូរេនិទាន ពណ៌នាអំពីពោធិសត្វច្យុតចាកឋានតុសិតទេវលោក មកកើតជាព្រះសិទ្ធត្ថកុមារ ក្នុងសាក្យត្រកូល ដរាបដល់បានត្រាស់ជាព្រះពុទ្ធ លើរតនបល្ល័ង្កក្រោមដើមពោធិព្រឹក្ស ។ ទី ៣ ហៅថា សន្តិកេនិទាន ពណ៌នាអំពីព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ហើយទ្រង់ស្តេចត្រាច់ចរប្រោសសត្វ គង់ក្នុងទីនោះ ៗ ដរាបដល់ចូលមហាបរិនិព្វាន ។

និទានទាំង ៣ នេះ ត្រូវតែរួបរួមបោះពុម្ពជាសៀវភៅ ១ ភាគ ប៉ុន្តែសម្តេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណោ ជួន-ណាត) សង្ឃនាយកជាប្រធាននៃគណៈកម្មការធម្មវិន័យ បានផ្តៀងផ្តាត់គំនិត កែសម្រួល

យល់ឃើញថា ត្រូវបោះពុម្ពរំលែកជា ៣ ភាគវិញ ដើម្បីកុំឲ្យសៀវភៅនេះមានកម្រាស់ក្រាស់ពេក តាំងឲ្យទាន់ពេលសិក្សារបស់សិក្ខាកាមកុលបុត្រ បណ្តើរៗ ទៅសិនផង, លុះដល់អនាគត សឹមបោះពុម្ពរួមជាសៀវភៅតែមួយភាគក៏បាន ។

ដោយហេតុដូច្នេះ បានជាពុទ្ធប្បវត្តិនេះ រៀបរៀងបោះពុម្ពរំលែកជា ៣ ភាគ តាមនិទានទាំង ៣ គឺ ទូរេនិទាន ភាគ ១, អវិទូរេនិទាន ភាគ ២, សន្តិកេនិទាន ភាគ ៣ ។

សូមឲ្យការសិក្សាធម្មវិន័យរបស់សិក្ខាកាមកុលបុត្រទាំងឡាយ ដល់នូវការលូតលាស់ចម្រើនជាតិយោភាពអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ ។

ថ្ងៃទី ២០ ធ្នូ ២៥២៥/១៩៨១

គណៈកម្មការធម្មវិន័យ

## បណាមគាថា

វន្ទិត្វា សិរសា សេដ្ឋំ ពុទ្ធប្បដិបុគ្គលំ
ញេយ្យសាគរមុត្តិណ្ណំ តិណ្ណសំសារសាគរំ
តថេវ បរមំ សន្តំ គម្ភីរំ ទុទ្ទសំ អណុំ
ភវាភវករំ សុទ្ធំ ធម្មំ សម្ពុទ្ធបូជិតំ
តថេវ បង សង្ឃញ្ច អសង្គំ សង្ឃបុត្តំ
ឧត្តមំ ទក្ខិណេយ្យានំ សន្តិន្ទ្រិយំ អនាសវំ
បរេតាធិប្បវត្តិញ្ញ ការិស្សំ យាវ ជីវិតា
តស្មា សិក្ខន្តុ សក្កច្ចំ តំ សិក្ខាកាមសាធវោ ។

ខ្ញុំព្រះអង្គ សូមថ្វាយបង្គំ ដោយសិរសាត្បូង ចំពោះព្រះសព្វញ្ញុ-ពុទ្ធ ទ្រង់ប្រសើរផុតពីគេពុំគួរប្រៀបបាន ទ្រង់បានឆ្លងផុតសង្សារសាគរ ឆ្លងទៅកាន់សាគរគឺញេយ្យធម៌ហើយ ។

មួយទៀត សូមថ្វាយបង្គំ ចំពោះព្រះធម៌ថ្លៃ ជាធម៌ប្រាប់បង់ផ្លូវ កាត់កិលេស ជាធម៌ល្អិតជ្រាលជ្រៅ កម្រសត្វឃើញបានដោយងាយ ជាធម៌ធ្វើភពតូចនិងភពធំឲ្យជ្រះស្រឡះ ជាព្រះសទ្ធម្មដែលទេវតានិងមនុស្សទាំងឡាយគោរពបូជា ។

មួយវិញទៀត សូមថ្វាយបង្គំ ចំពោះព្រះសង្ឃ ដែលមិនមាន ការជាប់ជំពាក់ដោយភាគកិលេស ជាព្រះសង្ឃខ្ពង់ខ្ពស់ ប្រសើរជាង

ទក្ខិណេយ្យបុគ្គលទាំងឡាយ ជាព្រះសង្ឃមានឥន្ទ្រិយស្ងប់រៀបរយ ជាព្រះសង្ឃមិនមានអាសវកិលេស ។

ដោយអំណាចដែលបាននមស្ការ ចំពោះព្រះរត្នត្រ័យនេះរួចហើយ នឹងពណ៌នានូវប្រវត្តិនៃព្រះសព្វញ្ញុពុទ្ធ តាំងពីកសាងជាដំបូងមក ដរាបដល់ចូលព្រះនិព្វានជាទីបំផុត, ព្រោះហេតុនោះ សាធុជនដ៏សិក្ខាកាមទាំងឡាយ គួរសិក្សានូវប្រវត្តិនៃព្រះសព្វញ្ញុពុទ្ធនោះ ដោយសេចក្តីគោរពចុះ ។

---

# ពុទ្ធប្បវត្តិ

## ទូរេនិទាន

### សុមេធកថា

មានសេចក្ដីតំណាលថា ក្នុងអតីតកាល ព្រះសម្មាសម្ពុទ្ធជាបរមសាស្ដានៃយើង កាលដែលព្រះអង្គតាំងនៅក្នុងឋានៈជាពោធិសត្វ កំពុងស្វែងរកពោធិញ្ញាណ បានយោនយកកំណើតកើតជាព្រាហ្មណ៍ នាម **សុមេធបណ្ឌិត** ជាឧភតោសុជាត មានរូបល្អ គួរជាទីពិតពិលរមិលមើល គួរជាទីជ្រះថ្លានៃមហាជន អាស្រ័យនៅក្នុងនគរឈ្មោះអមរវតី រាប់ពីត្រឹមភទ្ទកប្បនេះថយក្រោយទៅ បានបួនអសង្ខេយ្យ និងមួយសែនកប្ប ។

សុមេធបណ្ឌិតនោះ កើតក្នុងត្រកូលស្ដុកស្ដម្ភ ជាអ្នកមានភោគសម្បត្តិច្រើន តាំងជាអ្នករៀនចេះចប់ត្រៃវេទ ។ លុះអំណើះ ឥតពីមាតាបិតាទៅ នាយឃ្លាំងបាននាំយកអាយុបាត្តកៈ (បញ្ជីកត់ចំនួនទ្រព្យសម្បត្តិ) មកសូត្រជម្រាបជូនថា ទ្រព្យមានចំនួនប៉ុណ្ណេះជារបស់បិតា, ទ្រព្យមានចំនួនប៉ុណ្ណេះជារបស់មាតា, ទ្រព្យមានចំនួនប៉ុណ្ណេះជារបស់ជីដូនជីតានៃអ្នក, ចូរអ្នកគ្រងទ្រព្យនោះចុះ ។

សុមេធបណ្ឌិត កាលបើបានស្ដាប់ពាក្យនេះហើយ ក៏មានសេចក្ដីសង្វេគគិតថា ឱហ្ន៎ ! ញាតិទាំងឡាយមានជីដូនជីតា របស់អាត្មាអញ

ជាដើម មិនអាចប្រមូលយកទ្រព្យទាំងអស់នោះទៅកាន់បរលោក សូម្បីតែមួយកហាបណៈ ក៏យកទៅតាមខ្លួនពុំបានសោះឡើយ, អាត្មាអញ គួរធ្វើឧបាយណាមួយនឹងនាំយកទ្រព្យនេះទៅឲ្យបាន ។

ថ្ងៃមួយ សុមេធបណ្ឌិត ចូលទៅសម្ងំក្នុងទីស្ងាត់ នាផ្ទៃប្រាសាទជាន់លើ អង្គុយរំពឹងគិតថា ការកើតក្នុងភពថ្មីទៀត និងការបែកធ្លាយសរីរៈ ( ស្លាប់ ) រឿយៗ ក្នុងវដ្តសង្សារនេះ រមែងនាំមកនូវទុក្ខ, កង្វល់នេះ អាត្មាអញ មានជាតិ, ជរា, ព្យាធិ និងមរណៈជាធម្មតា, បើដូច្នេះ គួរតែអាត្មាអញ ស្វែងរកមហានិព្វានដែលជាធម្មជាតមិនមានជាតិ មិនមានជរា មិនមានព្យាធិ មិនមានមរណៈ មានតែសុខត្រជាក់តែប៉ុណ្ណោះ, គួរតែអាត្មាអញលះបោលនូវកាយសម្ពុយនេះ ដែលពេញដោយលាមកសពផ្សេងៗ ហើយចេញទៅបួស កុំមានសេចក្ដីអាឡោះអាល័យ ហើយស្វែងរកមាគ៌ាជាឧបាយដើម្បីដោះខ្លួនចេញឲ្យផុតអំពីភពនេះ ។

សុមេធបណ្ឌិត គិតយ៉ាងនេះទៀតថា ដែលពិត ក្នុងលោក តាមតែធម្មជាតអ្វីក៏ដោយ សុទ្ធតែមានជាគូៗនឹងគ្នា បើទុក្ខមាន ចំណែក-ខាងសុខក៏គង់មាន, បើភពមាន ចំណែកការធ្វើឲ្យផុតអំពីភពក៏គង់មាន, បើក្ដៅមាន ត្រជាក់ក៏គង់មាន, បើភ្លើងទាំង ៣ មានភ្លើងគឺរាគៈជាដើម មាន ធម្មជាតសម្រាប់លត់នូវភ្លើងទាំង ៣ នេះក៏គង់មាន, បើបាបមាន

បុណ្យក៏កើតមាន, បើជាតិ (កំណើត) មាន ធម្មជាតមួយមិនឲ្យមានកំណើតក៏កើតបាន ។

តពីនេះទៅទៀត សុមេធបណ្ឌិតគិតថា បុរសដែលធ្លាក់ទៅក្នុងរណ្ដៅ ប្រឡាក់ដោយលាមកហើយ ក្រឡេកមើលពីចម្ងាយទៅ ឃើញស្រះដ៏ដេរដាសដោយផ្កាឈូក, បុរសនោះគួរតែដើរទៅស្វែងរកទឹកក្នុងស្រះនោះដោយគិតថា អាត្មាអញគប្បីចុះទៅក្នុងស្រះនោះតាមផ្លូវណា ? បើបុរសនោះមិនស្វែងរកទឹកមកលាងជម្រះកាយឲ្យបានស្អាតបាតទេ ការមិនស្វែងរកនោះ ក៏មិនមែនជាទោសរបស់ស្រះទេ គឺជាទោសរបស់បុរសនោះឯង យ៉ាងណាមិញ, កាលបើស្រះពោលគឺអមតមហានិព្វាន ដែលជាគ្រឿងលាងជម្រះនូវមន្ទិលគឺកិលេសរបស់បុគ្គលមាន ប៉ុន្តែបុគ្គលនោះមិនស្វែងរក ការមិនស្វែងរកនោះ ក៏មិនមែនជាទោសរបស់ស្រះពោលគឺអមតមហានិព្វាននោះទេ គឺជាទោសរបស់បុគ្គលនោះឯង ក៏យ៉ាងនោះដែរ ។ មួយទៀត បុរស ដែលត្រូវសត្រូវគឺចោរ ចោមរោមព័ទ្ធជិតជុំវិញខ្លួនហើយ ឯផ្លូវសម្រាប់បុរសនោះរត់គេចចេញទៅក៏មាន ប៉ុន្តែបុរសនោះ មិនរត់គេចចេញទេ ក៏មិនមែនជាទោសរបស់ផ្លូវ គឺជាទោសរបស់បុរសនោះឯង យ៉ាងណាមិញ, បុរស ដែលត្រូវសត្រូវគឺកិលេស ចោមរោមព័ទ្ធជុំវិញខ្លួនហើយ ឯផ្លូវជាដំណើរទៅកាន់ព្រះនិព្វានមាន ប៉ុន្តែបើបុរសនោះ

មិនស្វែងរកគេ ការមិនស្វែងរកគេនោះ ក៏មិនមែនជាទោសរបស់មគ្គជាដំណើរទៅកាន់ព្រះនិព្វានទេ គឺជាទោសរបស់បុរសនោះឯង ក៏យ៉ាងនោះដែរ ។ មួយវិញទៀត បុរសដែលត្រូវជំងឺបៀតបៀនកាយឲ្យឈឺចាប់ជានិច្ចកាល ឯពេទ្យសម្រាប់ព្យាបាលជំងឺមាន ប៉ុន្តែបើបុរសនោះ មិនស្វែងរកពេទ្យនោះឲ្យមកព្យាបាលជំងឺទេ ក៏មិនមែនជាទោសរបស់ពេទ្យ គឺជាទោសរបស់បុរសនោះឯង យ៉ាងណាមិញ, បុរសណា ដែលត្រូវជំងឺគឺកិលេសបៀតបៀនហើយ មិនស្វែងរកអាចារ្យអ្នកឈ្លាសវៃប៉ិនប្រសប់ក្នុងការរម្ងាប់នូវកិលេស ឯអាចារ្យនោះប្រាកដជាមាន ប៉ុន្តែបុរសនោះមិនស្វែងរកគេ ការមិនស្វែងរកគេនោះឯង ជាក់ជាទោសរបស់បុរសនោះតែម្យ៉ាង មិនមែនជាទោសរបស់អាចារ្យនោះទេ ក៏យ៉ាងនោះដែរ ។

ក្រៅពីនេះទៀត សុំលើកបញ្ហាគិតថា បុរសប្រកបដោយជាតិជាអ្នកស្អិតស្អាតកាយ រមែងលះចោលនូវសាកសពជារបស់បដិកូល ដែលជាប់ព្យួរក ហើយគេចចេញទៅកាន់ទីដែលមានសេចក្តីសុខ យ៉ាងណាមិញ, កុលបុត្តគួរតែលះចោលនូវកាយស្អុយនេះ កុំមានសេចក្តីអាឡោះអាល័យ ហើយចូលទៅកាន់នគរគឺព្រះនិព្វាន ក៏យ៉ាងនោះដែរ ។ មួយទៀត ជនប្រុសស្រីទាំងឡាយ បន្ទោបង់ នូវឧច្ចារៈនិងបស្សាវៈក្នុងវច្ចកុដិ (បង្គន់) រួចហើយ មិនកាន់យកនូវឧច្ចារៈនិងបស្សាវៈនោះដោយថ្នាក់ ឬដោយ

ដោយសំពត់យកទៅទេ រមែងខ្ពើមរអើមលះបោលឥតមានសេចក្តីអាឡោះអាល័យដើរចេញទៅ យ៉ាងណាមិញ; អាត្មាអញ គួរតែលះបោលនូវកាយស្អុយនេះ កុំមានសេចក្តីអាឡោះអាល័យឡើយ ហើយចូលទៅកាន់នគរគឺព្រះនិព្វាន ក៏យ៉ាងនោះដែរ ។ មួយវិញទៀត ម្ចាស់ទូករមែងលះបោលទូកចាស់គ្រាំគ្រាដែលប្រើការមិនកើត ដើរចេញទៅដោយមិនមានសេចក្តីអាឡោះអាល័យ យ៉ាងណាមិញ; អាត្មាអញ នឹងលះបោលកាយស្អុយនេះ ដែលកំពុងហូរខ្ទុះឈាមចេញតាមបុរទ្វារទាំង ៩ ដោយមិនមានសេចក្តីអាឡោះអាល័យ ហើយចូលទៅកាន់បុរីនិព្វាន ក៏យ៉ាងនោះដែរ ។ ពុំនោះ ដូចបុរស នាំយករតនៈផ្សេងៗ ដើរទៅកាន់ផ្លូវជាមួយនឹងពួកចោរ លុះមានសេចក្តីខ្លាចអំពីការវិនាសនៃរតនៈរបស់ខ្លួន ក៏លះបង់ពួកចោរចេញ ហើយដើរទៅកាន់ផ្លូវដទៃដែលជាផ្លូវក្សេម យ៉ាងណាមិញ; ករជកាយនេះ ប្រហែលគ្នានឹងពួកចោរដែលមានបំណងនឹងប្លន់យករតនៈដែរ, បើអាត្មាអញ នឹងធ្វើនូវបំណងពេញចិត្តក្នុងករជកាយនេះ រតនៈគឺកុសលធម៌ នឹងសម្បយុត្តដោយអរិយមគ្គ គង់តែនឹងវិនាសពុំខាន, ព្រោះហេតុនោះ ៈ អាត្មាអញ គួរតែលះករជកាយដែលប្រហែលគ្នានឹងចោរនេះចោលចេញ ហើយចូលទៅកាន់នគរគឺនិព្វាន ក៏យ៉ាងនោះដែរ ។

លុះសុមេធបណ្ឌិតត្រិះរិះគិតប្រកបដោយនេក្ខម្មៈ (ការចេញបួស) ដោយសេចក្តីឧបមាឧបមេយ្យផ្សេងៗយ៉ាងនេះហើយ ក៏បរិច្ចាគភោគទ្រព្យ

របស់ខ្លួន ដល់ជនទាំងឡាយដែលត្រូវចែករំលែក ហើយបានឲ្យទានដល់
សព្វទាំងឡាយ និងមនុស្សច្រើនប្រទេស ដែលត្រូវសេចគ្រោះ មានមនុស្ស
កំព្រានិងមនុស្សអ្នកដំណើរដែលខ្វះខាតស្បៀងអាហារជាដើម ៗ លំដាប់
ពីនោះមក សុមេធបណ្ឌិត ក៏លះកាមទាំងឡាយ ចេញចាកនគរអមរវតី
ទៅតែម្នាក់ឯង ដើរសំដៅចូលទៅក្នុងព្រៃហិមពាន្ត ធ្វើបណ្ណសាលាជា
កស្រមនិងចង្ក្រមតាមកម្លាំងបុណ្យរបស់ខ្លួន អាស្រ័យនូវធម្មិកបពិតក្នុង
ព្រៃហិមពាន្តនោះឯង ហើយក៏លះបង់សំពត់សាដកប្រកបដោយទោស ៩
យ៉ាង(១) ចេញ ហើយបួសជាតាបសស្លៀកសំពត់សំបកក្រចៅ ប្រកប
ដោយគុណ ១២ យ៉ាង(២) ។ លុះបួសយ៉ាងនេះរួចហើយ ក៏លះបង់នូវ
បណ្ណសាលាដែលប្រកបដោយទោស ៨ យ៉ាង(៣) ចេញ ហើយចូលទៅ
នៅអាស្រ័យទីគល់ឈើដែលប្រកបដោយគុណ ១០ យ៉ាង(៤), លះបង់
នូវអាហារ ដែលធ្វើដោយធញ្ញជាតិទាំងពួងចេញ ហើយបរិភោគតែផ្លែ
ឈើដែលជ្រុះឯង, តាំងព្យាយាមដំបំដោយអំណាចត្រឹមតែឥរិយាបថ ៣.
គឺអង្គុយ, ឈរ និងការដើរចង្ក្រម បិនយូរប៉ុន្មានក៏បានសម្រេចសមាបត្តិ ៨
និងអភិញ្ញា ៥ ក្នុងរវាង ៧ ថ្ងៃប៉ុណ្ណោះ ។ សុមេធបណ្ឌិត បានសម្រេច
អភិញ្ញាពល ប្រព្រឹត្តទៅដោយសេចក្ដីសុខក្នុងសមាបត្តិ យ៉ាងនេះឯង ។

---

១-២-៣-៤ មាននៅក្នុងរត្នបិដកភាគ គម្ពីរឯកនិបាត, ក្នុងទីនេះ មិនបានស្រង់មាតិកា
យកមករៀបរៀងទេ ព្រោះចៀសវាងកុំឲ្យសៀវភៅនេះមានកម្រាស់ក្រាស់ពេក ។

## ១– ទីបង្ករកថា

ក្នុងកាលនោះ សម្តេចព្រះទសពលព្រះនាម ទីបង្ករ បានត្រាស់ឡើងក្នុងលោក មានភិក្ខុសង្ឃជាព្រះខីណាស្រពចំនួនបួនសែនអង្គ ហែហមរោមរោមជាបរិវារ ទ្រង់ស្តេចទៅ កាន់ជនបទចារិកតាមលំដាប់, លុះស្តេចទៅដល់នគរឈ្មោះរម្មកៈ(១) ទ្រង់អាស្រ័យនៅក្នុងសុទស្សនមហាវិហារ ។ ពួកមហាជនដែលនៅក្នុងក្រុងរម្មកៈ បានឮដំណឹងថា ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់បានដល់បរមាភិសម្ពោធិញ្ញាណ បានធម្មចក្រដ៏ប្រសើរប្រព្រឹត្តទៅហើយ ទ្រង់ស្តេចមកគង់ក្នុងសុទស្សនមហាវិហារ, ក៏នាំគ្នាយកភេសជ្ជៈ មានសប្បិនិងនវនីតជាដើម ព្រមទាំងគ្រឿងសក្ការៈ មានសំពត់និងផ្កាកម្រងជាដើម ចូលទៅធ្វើសក្ការបូជា ស្តាប់ព្រះធម៌ទេសនា ។ លុះចប់ព្រះធម៌ទេសនាហើយ ក៏និមន្តព្រះសម្ពុទ្ធព្រមទាំងភិក្ខុសង្ឃ សូមឲ្យទទួលភត្ត ក្នុងវេលាថ្ងៃស្អែក ។ លុះដឹងថាព្រះអង្គបានទទួលនិមន្តហើយ ក៏នាំគ្នាថ្វាយបង្គំ ហើយក្រោកចាកអាសនៈដើរចេញទៅ ។ លុះដល់ថ្ងៃព្រឹកឡើង ពួកមហាជនដែលនៅក្នុងក្រុងរម្មកៈទាំងនោះ នាំគ្នាតាក់តែងមហាទាន ព្រមទាំងរៀបចំបម្រុងផ្លូវ ដើម្បីព្រះទសពលញាណទ្រង់ស្តេចចូលមកក្នុងក្រុង ។

១ គម្ពីរដទៃពុំនេះថា ឈ្មោះ អមរៈ ឬ អមរវតី ។

ក្នុងខណៈនោះ សុមេធបណ្ឌិតដែលបួសជាតាបសនៅនាព្រៃហិមពាន្តបាន សម្រេចឈាននិងអភិញ្ញា ជួនជាមានដំណើរមកតាមនភាល័យ ក្រឡេកមើលទៅឃើញមហាជនមីរដេសដាស កំពុងតែរៀបចំធ្វើផ្លូវដើម្បីថ្វាយព្រះលោកនាថព្រះនាមទីបង្ករ ដែលនឹងទ្រង់ស្ដេចចេញអំពីសុទស្សនមហាវិហារចូលទៅកាន់ក្រុងរម្មកៈ, ក៏ចុះអំពីអាកាសមកហើយសួរមនុស្សទាំងឡាយ, បានដឹងសេចក្ដីសព្វគ្រប់ហើយ ក៏ទទួលនាទីមួយកន្លែង ដើម្បីធ្វើដោយខ្លួនឯង ៗ កាលបើផ្លូវដែលសុមេធតាបសធ្វើនោះមិនទាន់ស្រេចនៅឡើយ(១) ស្រាប់តែ ព្រះសម្មាសម្ពុទ្ធ ទ្រង់ស្ដេចមកដល់ ៗ សុមេធតាបស យកស្បែកខ្លាទាំងក្រចក ក្រាលលើភក់រួចប្រះខ្លួនដេកសន្ធឹងធ្វើជាស្ពាន, បើកភ្នែកសម្លឹងមើលពុទ្ធសិរី នៃព្រះទសពលទ្រង់ព្រះនាមទីបង្ករ, គិតយ៉ាងនេះថា បើប្រសិនជាអាត្មាអញ ប្រាថ្នាឲ្យអស់អាសវក្កិលេសពីខន្ធសន្ដាន ដើម្បីលុះនូវព្រះនិព្វានជាប្រយោជន៍ចំពោះខ្លួនឯងក្នុងជាតិនេះ ក៏នឹងបានដោយពិត, ប៉ុន្តែមិនដូច្នោះ, គួរអាត្មាអញ ប្រាថ្នា

---

១ សួរថា សុមេធតាបសបានសម្រេចឈាននិងអភិញ្ញាប្រកបដោយឫទ្ធិជាលោកិយគ្រប់គ្រាន់ហើយ ចុះហេតុអ្វីបានជាធ្វើផ្លូវប៉ុណ្ណោះមិនឲ្យហើយ? ឆ្លើយថា សុមេធតាបសបរិបូណ៌ដោយឫទ្ធិជាលោកិយក៏ពិតមែន ប៉ុន្តែលោកគិតថា បើអាត្មាអញតាក់តែងផ្លូវនេះដោយឫទ្ធិឲ្យជាប់រហ័សទាន់ពេលក៏បាន កាលបើធ្វើយ៉ាងនេះទៅ ចិត្តរបស់អាត្មាអញក៏មិនសូវរីករាយប៉ុន្មានគួរតែអាត្មាអញខំប្រឹងធ្វើដោយកាយប្រព្រឹត្តិវិញ ។ ដោយហេតុនេះ បានជាមានដំណើរមិនលោះផ្លូវនោះ ។

ឲ្យបានបរមាភិសម្ពោធិញ្ញាណ ដូចជាព្រះពុទ្ធ ព្រះនាមទីបង្ករនេះ ហើយទើបបើកមហាទ្វារគឺព្រះធម៌ ចម្លងមហាជនឲ្យឆ្លងផុតចាកសាគរគឺសង្សារ ហើយសឹមបរិនិព្វានទៅយ៉ាងឯងក្នុងកាលខាងក្រោយ, បំណងនេះ ទើបជាកិច្ចដ៏សមគួរដល់អាត្មាអញ ។

ក្នុងវេលាដែលសុមេធតាបសធ្វើនូវអភិនីហារ (ការតសាង) ដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធនោះ លោកប្រកបដោយធម្មសមោធាន ៨ ប្រការគឺ

១– មនុស្សត្តំ ភាពជាមនុស្ស[១];

២– លិង្គសម្បត្តិ ដល់ព្រមដោយភេទ គឺភេទប្រុស[២];

៣– ហេតុ ប្រកបដោយហេតុ គឺមានឧបនិស្ស័យគួរនឹងបានសម្រេចអរហត្តផល,

៤– សត្ថារទស្សនំ បានជួបនឹងព្រះសាស្តា គឺ ព្រះសម្មាសម្ពុទ្ធ (៣);

៥– បព្វជ្ជា បានបួសក្នុងព្រះពុទ្ធសាសនា ឬ បួសជាតាបសខាងក្រៅព្រះពុទ្ធសាសនា;

---

១ តិរច្ឆានមាននាគនិងគ្រុឌជាដើមក្ដី អមនុស្សមានទេវតាជាដើមក្ដី ប្រាថ្នានូវពុទ្ធភូមិពុំសម្រេចឡើយ ។ ២ ស្ត្រីភេទក្ដី បណ្ឌកភេទក្ដី ឧភតោព្យញ្ជនកភេទក្ដី ប្រាថ្នានូវពុទ្ធភូមិពុំសម្រេចឡើយ ។ ៣ បើព្រះពុទ្ធបរិនិព្វានទៅហើយ ប្រាថ្នានូវពុទ្ធភូមិចំពោះចេតិយក្ដី ចំពោះគល់នៃពោធិព្រឹក្សក្ដី ពុំសម្រេចឡើយ ។

៦– គុណសម្បត្តិ ដល់ព្រមដោយគុណធម៌មានឈានជាដើម;

៧– អធិការោ ប្រកបដោយអធិការ គឺមានសេចក្ដីកសាងធំក្ដៃក្ដស់ហានលះជីវិតបរិច្ចាគជាដើម,

៨– ឆន្ទតា ហានសេចក្ដីពេញចិត្តប្រាថ្នានូវពោធិញ្ញាណ ។

ចំណែកខាងព្រះបរមសាស្ដា ទ្រង់ព្រះនាមទីបង្ករ កាលបើស្ដេចយាងធ្លងផុតពីភក់នោះហើយ ទ្រង់ព្យាករក្នុងកណ្ដាលបរិស័ទថា "អ្នកទាំងឡាយ ចូរមើលតាបសដែលកំពុងដេកលើភក់នេះ មានតបះដ៏ខ្ពង់ខ្ពស់, ចំណេរកាលទៅអនាគត រាប់ពីត្រឹមកប្បនេះទៅនៅបួនអសង្ខេយ្យនិងមួយសែនកប្បទៀត តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គព្រះនាមគោតម ។ នគរជាលំនៅរបស់ព្រះពុទ្ធនោះ ឈ្មោះកបិលព័ស្ដុ, ព្រះមាតាព្រះនាមមហាមាយាទេវី, ព្រះបិតាព្រះនាមសុទ្ធោទនៈ, មានភិក្ខុឈ្មោះឧបតិស្សៈ (សារីបុត្ត) ជាអគ្គសាវ័ក, ភិក្ខុឈ្មោះកោលិតៈ (មោគ្គល្លាន) ជាទុតិយសាវ័ក, ភិក្ខុឈ្មោះអានន្ទជាពុទ្ធុបដ្ឋាក, ភិក្ខុនីឈ្មោះខេមាជាអគ្គសាវិកា, ភិក្ខុនីឈ្មោះឧប្បលវណ្ណា ជាទុតិយសាវិកា, វេលាមានព្រះញាណចាស់ក្លា នឹងចេញទ្រង់ព្រះផ្នួសធ្វើទុក្ករកិរិយាអស់ ៦ វស្សា បានទទួលបតុបាយាសទៀបគល់និគ្រោធព្រឹក្ស យកទៅសោយត្រង់ឆ្នេរស្ទឹង

នៅញ្ញូក លុះដល់សាយណ្ហសម័យ នឹងឡើងកាន់ពោធិមណ្ឌល ហើយ នឹងបានត្រាស់ជាព្រះពុទ្ធទៀបគល់នៃអស្សត្ថព្រឹក្ស ( ដើមពោធិ ) " ។

សុមេធបណ្ឌិត កាលបើបានស្តាប់ព្យាករណ៍ អំពីសំណាក់នៃព្រះទសពល ព្រះនាមទីបង្ករហើយ ក៏ធ្វើសេចក្តីសន្និដ្ឋានថា " អាត្មាអញមុខជានឹងបានត្រាស់ជាព្រះពុទ្ធដោយពិត " ។ ហើយពិចារណាស្ទាបស្ទង់នូវពុទ្ធការកធម៌ថា ធម៌ដែលធ្វើឲ្យបុគ្គលបានត្រាស់ជាព្រះពុទ្ធនោះ មាននៅក្នុងទីណា, ឋិតនៅខាងលើឬខាងក្រោម, ឋិតនៅក្នុងទិសធំឬទិសតូច; កំពុងតែពិចារណារកពុទ្ធការកធម៌តាមលំដាប់ទៅ ក៏បានឃើញនូវទានបារមីជាបឋម ដែលបុរាណកពោធិសត្វទាំងឡាយ តែងសេពគប់រួចមកហើយ, ទើបទូន្មានខ្លួនថា នែសុមេធបណ្ឌិត ចាប់ដើមពីត្រឹមថ្ងៃនេះទៅ អ្នកឯងត្រូវបំពេញទានបារមីជាបឋម ប្រៀបដូចក្អមដែលពេញដោយទឹកដែលគេផ្កាប់ចុះបង្ហូរទឹកចេញមិនឲ្យមានសេសសល់ ហើយទឹកនោះឯង ក៏មិនអាចហូរត្រឡប់ចូលមកវិញបានឡើយ យ៉ាងណាមិញ, អ្នកឯង កុំត្រឡប់មើលទ្រព្យ, យស, កូន, ប្រពន្ធនិងអវយវៈតូចធំឡើយ; កាលបើមានពួកស្មូមមកសូមរបស់អ្វីៗ ត្រូវតែឲ្យរបស់នោះទាំងអស់ តាមបំណងរបស់ពួកស្មូម កុំឲ្យមានសេសសល់ឡើយ ក៏យ៉ាងនោះដែរ, ទើបអ្នកឯង នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។

សុមេធបណ្ឌិត បានពេញនូវទានបារមីជាប្រថម ដំបាំដោយប្រការយ៉ាងនេះហើយ ក៏ពិចារណាថា មិនមែនមានត្រឹមតែពុទ្ធការកធម៌នេះប៉ុណ្ណោះទេ គង់មានធម៌ដទៃក្រៅពីនេះទៀត ។ លុះពិចារណាតទៅក៏បានឃើញសីលបារមីទី ២ ដែលបោរាណកពោធិសត្វទាំងឡាយបានសមាទានប្រព្រឹត្តរួចមកហើយ ទើបទូន្មានខ្លួនថា នែសុមេធបណ្ឌិត តាំងដើមពីត្រឹមថ្ងៃនេះទៅ អ្នកឯងត្រូវបំពេញសីលបារមី ប្រៀបដូចជាម្រឹគចាមរី, ធម្មតាម្រឹគចាមរី ស៊ូប្រថុយលះបង់ជីវិត ចាំរក្សាការពារសក់កន្ទុយរបស់ខ្លួនមិនឲ្យប្រឡាក់សៅហ្មង យ៉ាងណាមិញ, អ្នកឯងពីត្រឹមថ្ងៃនេះទៅ ត្រូវប្រថុយលះបង់ជីវិត រក្សាតែសីលឲ្យបានហ្មត់ចត់កុំឲ្យសៅហ្មង ក៏យ៉ាងនោះដែរ, ទើបអ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។

កាលសុមេធបណ្ឌិតអធិដ្ឋានសីលបារមីទី ២ ឲ្យមាំដោយប្រការយ៉ាងនេះហើយ ក៏ពិចារណាថា មិនមែនមានត្រឹមតែពុទ្ធការកធម៌ទាំងឡាយនេះប៉ុណ្ណោះទេ គង់មានធម៌ដទៃពីនេះទៀត ។ លុះពិចារណាតទៅ ក៏បានឃើញនេក្ខម្មបារមីទី ៣ ដែលបោរាណកពោធិសត្វទាំងឡាយ ធ្លាប់បានសមាទានប្រព្រឹត្តរួចមកហើយ ទើបទូន្មានខ្លួនថា នែសុមេធបណ្ឌិត តាំងដើមតាំងពីថ្ងៃនេះទៅ អ្នកឯងត្រូវបំពេញនេក្ខម្មបារមី ប្រៀបដូចជាបុរសដែលនៅក្នុងពន្ធនាគារ (គុក) តែងអផ្សុកធុញទ្រាន់មិនចង់នៅក្នុងពន្ធ-

នាគារនោះតទៅទៀត យ៉ាងណាមិញ, អ្នកឯងត្រូវសម្គាល់ថា ភពទាំងអស់ប្រហែលគ្នានឹងពន្ធនាគារ គួរតែអផ្សុកធុញទ្រាន់ចង់ចេញឲ្យផុតចាកភពទាំងអស់ ហើយបែរមុខឆ្ពោះទៅរកនេក្ខម្មៈ (ការចេញបួស) ក៏យ៉ាងនោះដែរ, ទើបអ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។

កាលសុមេធបណ្ឌិតអធិដ្ឋាននូវនេក្ខម្មបារមីទី ៣ ឲ្យមាំដោយប្រការយ៉ាងនោះហើយ ក៏ពិចារណាថា មិនមែនមានត្រឹមតែពុទ្ធការកធម៌ទាំង-ឡាយនេះប៉ុណ្ណោះទេ គង់មានធម៌ដទៃពីនេះទៀត ៗ លុះពិចារណាតទៅក៏បានឃើញបញ្ញាបារមីទី ៤ ដែលបោរាណកពោធិសត្វទាំងឡាយ ធ្លាប់បានសេពគប់ប្រព្រឹត្តរួចមកហើយ ទើបទូន្មានខ្លួនថា នៃសុមេធបណ្ឌិតចាប់ដើមពីត្រឹមថ្ងៃនេះតទៅ អ្នកឯងត្រូវបំពេញបញ្ញាបារមី ត្រូវកុំវៀរនូវបុគ្គលណាមួយ ទោះជាន់ទាបក្តី ជាន់កណ្តាលក្តី ជាន់ខ្ពស់ក្តី ឲ្យសោះហើយចូលទៅសេពគប់រកអ្នកប្រាជ្ញជាបណ្ឌិតសាកសួរនូវបញ្ហាផ្សេង ៗប្រៀបដូចភិក្ខុអ្នកចរទៅដើម្បីបិណ្ឌបាត មិនរើសអើង មិនវៀរនូវត្រកូលណាមួយ តែងត្រាច់ទៅបិណ្ឌបាតតាមលំដាប់ផ្ទះ ហើយឆាប់បានអាហារចម្អែតអាត្មា យ៉ាងណាមិញ, អ្នកឯង ត្រូវចូលទៅរកអ្នកប្រាជ្ញជាបណ្ឌិតទាំងឡាយដែលជាអ្នកមានការចេះដឹង ហើយសាកសួរនូវបញ្ហាផ្សេង ៗទើបអ្នកឯងនឹងឆាប់បានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ក៏យ៉ាងនោះដែរ ។

កាលសុមេធបណ្ឌិតអធិដ្ឋាននូវបញ្ញាបារមីទី ៤ ឲ្យមាំដោយប្រការយ៉ាងនេះហើយ ក៏ពិចារណាថា មិនមែនមានត្រឹមតែពុទ្ធការកធម៌ទាំង-ឡាយនេះប៉ុណ្ណោះទេ គង់មានធម៌ដទៃពីនេះទៀត ៗ លុះពិចារណាតទៅ ក៏បានឃើញវីរិយបារមីទី ៥ ដែលបោរាណកពោធិសត្វទាំងឡាយធ្លាប់បានសមាទានប្រព្រឹត្តរួចមកហើយ ទើបទូន្មានខ្លួនថា នែសុមេធបណ្ឌិត តាំងដើមតាំងពីថ្ងៃនេះតទៅ អ្នកឯង ត្រូវបំពេញវីរិយបារមី ប្រៀបដូចជាសត្វសីហៈជាស្តេចនៃម្រឹគ ជាសត្វមានព្យាយាមមាំក្នុងឥរិយាបថទាំង ៤ យ៉ាងណាមិញ, ចំណែកអ្នកឯង ក៏ត្រូវមានព្យាយាមមាំ មានព្យាយាមមិនរួញរាគ្រប់ឥរិយាបថទាំង ៤ ក្នុងកាលទាំងពួង ក៏យ៉ាងនោះដែរ, ទើបអ្នកឯង នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ៗ

កាលសុមេធបណ្ឌិតអធិដ្ឋានវីរិយបារមីទី ៥ ឲ្យមាំដោយប្រការយ៉ាងនេះហើយ ក៏ពិចារណាថា មិនមែនមានត្រឹមតែពុទ្ធការកធម៌ទាំងឡាយនេះប៉ុណ្ណោះទេ គង់មានធម៌ដទៃពីនេះទៀត ៗ លុះពិចារណាតទៅ ក៏បានឃើញខន្តិបារមីទី ៦ ដែលបោរាណកពោធិសត្វទាំងឡាយធ្លាប់បានសមាទានប្រព្រឹត្តរួចមកហើយ ទើបទូន្មានខ្លួនថា នែសុមេធបណ្ឌិត តាំងដើមពីត្រឹមថ្ងៃនេះទៅ អ្នកឯង ត្រូវបំពេញខន្តិបារមី បើទុកជាមានគេកាប់ពេន សរសើរ បញ្ជោរយ៉ាងណាក្តី គេមើលងាយបន្តុះបង្អាប់យ៉ាងណាក្តី

ត្រូវតាំងចិត្តអត់ទ្រាំ ប្រៀបដូចជាផែនដី, ធម្មតាផែនដី បើទុកជាគេដាក់វត្ថុស្អាតក្តី មិនស្អាតក្តី ផែនដីឥតត្រេកអរ ឥតថ្នាំងថ្នាក់អាក់អន់អ្វីចំពោះវត្ថុដែលគេដាក់នោះឡើយ, ផែនដីចេះតែអត់ធន់ ទទួលពិបរងបានគ្រប់មុខទាំងអស់ យ៉ាងណាមិញ, ចំណែកខាងអ្នកឯង ត្រូវតែអត់ធន់ចំពោះពាក្យសរសើរនិងពាក្យតិះដៀល របស់ជនផង ក៏យ៉ាងនោះដែរ, ទើបអ្នកឯង នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។

កាលសុមេធបណ្ឌិតអធិដ្ឋានខន្តិបារមីទី ៦ ឲ្យមាំដោយប្រការយ៉ាងនេះហើយ ក៏ពិចារណាថា មិនមែនមានត្រឹមតែពុទ្ធការកធម៌ទាំងឡាយនេះប៉ុណ្ណោះទេ គង់មានធម៌ដទៃពីនេះទៀត ។ លុះពិចារណាតទៅ ក៏បានឃើញសច្ចបារមីទី ៧ ដែលបោរាណកពោធិសត្វទាំងឡាយធ្លាប់បានសមាទានប្រព្រឹត្តរៀងមកហើយ ទើបទូន្មានខ្លួនថា នែសុមេធបណ្ឌិត តាំងដើមពីថ្ងៃនេះទៅ អ្នកឯង ត្រូវបំពេញសច្ចបារមី បើទុកជារន្ទះធ្លាក់ចុះមកលើអវៃយ្វក្បាលក្តី ឬគេយកវត្ថុមានទ្រព្យជាដើមមកឲ្យក្តី អ្នកឯងកុំធ្វើនូវសម្បជានមុសាវាទ (និយាយកុហកទាំងដឹងខ្លួន) ព្រោះតែរបស់ទាំងនោះឡើយ ប្រៀបដូចជាផ្កាយព្រឹក, ធម្មតាផ្កាយព្រឹក មិនដែលលះបង់វិថីជាដំណើររបស់ខ្លួនក្នុងរដូវទាំងពួង ទាំងមិនទៅក្នុងវិថីដទៃ រមែងទៅតែក្នុងវិថីរបស់ខ្លួនដដែល យ៉ាងណាមិញ, អ្នកឯង កុំលះបង់ពាក្យសច្ចៈ,

កុំនិយាយពាក្យមុសា ក៏យ៉ាងនោះដែរ, ទើបអ្នកឯង នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។

កាលសុមេធបណ្ឌិតអធិដ្ឋានសច្ចបារមី ៧ ឲ្យមាំដោយប្រការយ៉ាងនេះហើយ ក៏ពិចារណាថា មិនមែនមានត្រឹមតែពុទ្ធការកធម៌ទាំងឡាយនេះប៉ុណ្ណោះទេ គង់មានធម៌ដទៃពីនេះទៀត ។ លុះពិចារណាតទៅ ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលបុរាណកពោធិសត្វទាំងឡាយធ្លាប់បានសមាទានប្រព្រឹត្តរួចមកហើយ ទើបទូន្មានខ្លួនថា នែសុមេធបណ្ឌិត ចាប់ដើមពីត្រឹមថ្ងៃនេះទៅ អ្នកឯងត្រូវបំពេញអធិដ្ឋានបារមី, អ្នកឯងបានប្តេជ្ញាតាំងនៅក្នុងអធិដ្ឋានណា ត្រូវតាំងចិត្តឲ្យខ្ជាប់ខ្ជួនក្នុងអធិដ្ឋាននោះ កុំបីឲ្យមានការកម្រើករញ្ជួយឡើយ ប្រៀបដូចជាភ្នំ, ឥតម្នាភ្នំ មិនកម្រើក មិនរញ្ជួយ ដោយសារខ្យល់ដែលបក់បោកមកអំពីទិសទាំងពួង រមែងឋិតនៅនឹងថ្កល់ត្រង់កន្លែងរបស់ខ្លួនដដែល យ៉ាងណាមិញ; អ្នកឯង ក៏ត្រូវតាំងនៅក្នុងអធិដ្ឋានរបស់ខ្លួន កុំឲ្យមានការកម្រើករញ្ជួយឡើយ ក៏យ៉ាងនោះដែរ, ទើបអ្នកឯង នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។

កាលសុមេធបណ្ឌិតសមាទានអធិដ្ឋានបារមីទី ៨ ឲ្យមាំដោយប្រការយ៉ាងនេះហើយ ក៏ពិចារណាថា មិនមែនមានត្រឹមតែពុទ្ធការកធម៌ទាំង-ឡាយនេះប៉ុណ្ណោះទេ គង់មានធម៌ដទៃពីនេះទៀត ។ លុះពិចារណា

តទៅ ក៏បានឃើញមេត្តាបារមីទី ៩ ដែលបោរាណកពោធិសត្វទាំងឡាយ ធ្លាប់បានសមាទានប្រព្រឹត្តមកហើយ ទើបទូន្មានខ្លួនថា នែសុមេធបណ្ឌិត តាំងដើមពីត្រឹមថ្ងៃនេះទៅ អ្នកឯងត្រូវបំពេញនូវមេត្តាបារមី គឺមានចិត្តតែមួយចំពោះអំពើដែលមានប្រយោជន៍ផង ចំពោះអំពើដែលមិនមានប្រយោជន៍ផង ប្រៀបដូចជាទឹក, ធម្មតាទឹក រមែងជ្រួតជ្រាបធ្វើនូវភាពដ៏ត្រជាក់ ដល់បាបជនផង ដល់កល្យាណជនផង ដូចគ្នាតែមួយយ៉ាងណាមិញ, អ្នកឯង ត្រូវមានចិត្តតែមួយផ្សាយទៅដោយមេត្តាចិត្តចំពោះសព្វសត្វទាំងឡាយ ក៏យ៉ាងនោះដែរ, ទើបអ្នកឯង នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។

កាលសុមេធបណ្ឌិតអធិដ្ឋានមេត្តាបារមីទី ៩ ឲ្យមាំដោយប្រការយ៉ាងនេះហើយ ក៏ពិចារណាថា មិនមែនមានត្រឹមតែពុទ្ធការកធម៌ទាំងឡាយនេះប៉ុណ្ណោះទេ គង់មានធម៌ដទៃពីនេះទៀត ។ លុះពិចារណាតទៅ ក៏បានឃើញឧបេក្ខាបារមីទី ១០ ដែលបោរាណកពោធិសត្វទាំងឡាយ ធ្លាប់បានសមាទានប្រព្រឹត្តមកហើយ ទើបទូន្មានខ្លួនថា នែសុមេធបណ្ឌិត តាំងដើមពីត្រឹមថ្ងៃនេះទៅ អ្នកឯង ត្រូវបំពេញឧបេក្ខាបារមី គឺមានចិត្តនឹងនៅជាកណ្ដាល ៗ ចំពោះសុខផង ចំពោះទុក្ខផង ប្រៀបដូចជាផែនដី, ធម្មតាផែនដី បើគេដាក់វត្ថុស្អាតក្ដី មិនស្អាតក្ដី, ផែនដី

រៀបតាំងនៅជាកណ្តាល ៗ មិនមានសោមនស្សទោមនស្សឡើយ យ៉ាងណាមិញ, អ្នកឯង ក៏ត្រូវតាំងចិត្តជាកណ្តាល ៗ ចំពោះសុខនិងទុក្ខ ក៏យ៉ាងនោះដែរ, ទើបអ្នកឯង នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ៗ

កាលសុមេធបណ្ឌិតអធិដ្ឋានឧបេក្ខាបារមីទី ១០ ឲ្យមាំដោយប្រការយ៉ាងនេះហើយ គតិនេះទៅក៏គិតថា ពុទ្ធការកធម៌ ជាប្រធាននៃពោធិញ្ញាណ ដែលពោធិសត្វតាំងគួរត្រូវបំពេញក្នុងលោកនេះ, ឯពុទ្ធការកធម៌នោះ មិនមែនដទៃក្រៅពីបារមីទាំង ១០ នេះទេ, បារមីទាំង ១០ នោះឯង មិនមែនឋិតនៅ ក្នុងខាងលើ មិនមែនឋិតនៅឯអាកាស មិនមែនឋិតនៅខាងក្រោមផែនដី មិនមែនឋិតនៅក្នុងទិសទាំងឡាយ មានបុរត្ថិមទិស (ទិសខាងកើត) ជាដើមទេ ប្រាកដជាឋិតនៅសឹប់ ក្រសំចន្លោះសាច់ហឫទ័យនៃអាត្មាអញនេះឯង ៗ សុមេធបណ្ឌិត កាលបើយល់ច្បាស់ថា បារមីទាំងនោះឋិតនៅសឹប់ក្នុងហឫទ័យយ៉ាងនេះហើយ ក៏អធិដ្ឋានបារមីទាំងអស់ឲ្យតាំងនៅមាំ ហើយពិចារណារឿយ ៗ ជាអនុលោម (បណ្តោយចុះទៅ) ជាបដិលោម (ប្រាសត្រឡប់មកវិញ) គឺពិចារណាសាចុះសាឡើង ដូចគេបង្វិលត្រលុកប្រេងក្នុងយន្ត ពុំនោះសោតដូចគេយកកំពូលភ្នំសិនេរុ បកក្បូរត្រលុកទឹកក្នុងមហាសមុទ្រ ៗ កាលដែលសុមេធបណ្ឌិតនោះកំពុងពិចារណាបារមីទាំង ១០ មហាប្រឹថពីដែលមានកម្រាស់ ២ សែន ៤ ហ្មឺន

មហាជន ក៏កម្រើករញ្ជួយ បន្លឺសំឡេងលាន់ឮ ដូចជាដីរំជាក់ខ្លួនញាប់ បបុស, ពុំនោះសោត ដូចជាស្គរឃ្លាបដែលគេគាបសំពៅ ។ កាលដែលមហាប្រឹថពីកំពុងកម្រើករញ្ជួយយ៉ាងនេះ ពួកមហាជនដែលនៅក្នុងក្រុងរម្មកៈទាំងប៉ុន្មាន មិនអាចទប់ទល់អាត្មាបាន ក៏ដួលព្រេកព្រោក ហាក់ដូចជាដើមឈើធំ ៗ ដែលមានខ្យល់ព្យុះបក់បោកមកត្រូវ, មិនតែប៉ុណ្ណោះទៀយ សូម្បីភាជនៈមានក្អមឆ្នាំងជាដើម ក៏កម្រើករញ្ជួយប៉ះទង្គិចគ្នាបែកខ្ទេចខ្ទីដែរ ។ ចំណែកខាងមហាជន មានសេចក្តីភិតភ័យតក់ស្លុតមហិមា ក៏នាំគ្នាចូលទៅគាល់ទូលសួរព្រះសាស្តាព្រះនាមទីបង្ករថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនបានដឹងនូវភយខ្ពុកយទុំះទេ សូម្បីមហាជនទាំងពួង ក៏ត្រូវភយខ្ពុកយទុំះបៀតបៀនដែរ, តើបាបគ្រោះអ្វីកើតកេដល់លោកនេះឬ ឬក៏សោបគ្រោះ នឹងកើតមានដល់លោកនេះ ? សូមព្រះអង្គទ្រង់សម្តែងប្រាប់នូវហេតុនោះដល់យើងខ្ញុំព្រះអង្គ ។ ព្រះសាស្តា : កាលបើបានទ្រង់ព្រះសណ្តាប់ពាក្យមហាជននោះហើយ ក៏ត្រាស់ថា អ្នកទាំងឡាយ កុំខ្លាច កុំគិតទៀយ, ភយខ្ពុកយនឹងមិនកើតមានដល់អ្នកទាំងឡាយទេ · ដ្បិតថ្ងៃនេះ តថាគតបានព្យាករឲ្យសុមេធបណ្ឌិតថា នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម ក្នុងអនាគត ។

ឥឡូវនេះ សុមេធបណ្ឌិតនោះ កំពុងពិចារណាបារមី, ដោយអំណាចតេជធម៌ របស់សុមេធបណ្ឌិត ដែលបានពិចារណាបារមីនោះឯង ក៏បណ្តាលឲ្យលោកធាតុទាំង ១ ហ្មឺន កក្រើករញ្ជួយបន្លឺសំឡេងខ្ទរខ្ទារជាអស្ចារ្យ ដោយឯកប្រហារយ៉ាងនេះឯង ។

ពួកមហាជន កាលបានស្តាប់ព្រះពុទ្ធដីកានៃព្រះតថាគតហើយ ក៏មានចិត្តត្រេកអររីករាយ នាំគ្នាយកផ្កាកម្រងនិងគ្រឿងក្រអូបផ្សេងៗ ចូលទៅបូជាសុមេធបណ្ឌិតជាអគ្គពោធិសត្វ ហើយនាំគ្នាដើរប្រទក្សិណពោធិ-សត្វ រួចហើយទើបចូលទៅកាន់ក្រុងរម្មកៈវិញ ។

លំដាប់ពីនោះ ពួកទេវតាក្នុងសកលលោក ទាំង ១ ហ្មឺនចក្រវាឡ ប្រជុំគ្នាបូជាពោធិសត្វ ដោយផ្កាកម្រងនិងគ្រឿងក្រអូបជាទិព្វ ហើយក៏ពោលសរសើរ ព្រមទាំងឲ្យពរស័ព្ទសាធុការដល់ពោធិសត្វថា បពិត្រសុមេធតាបស សេចក្តីប្រាថ្នាដ៏ធំដែលលោកបានតាំងទុកទៀបបាទមូលនៃព្រះទសពលព្រះនាមទីបង្ករ សូមឲ្យសេចក្តីប្រាថ្នានោះ សម្រេចដល់លោក កុំបីមានអន្តរាយឡើយ, ភ័យក្តី សេចក្តីតក់ស្លុតក្តី កុំបីកើតមានដល់លោកឡើយ, សូមលោកបំពេញបារមីទាំងឡាយ ដើម្បីឲ្យបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណយ៉ាងឆាប់ ប្រៀបដូចដើមឈើ ដែលគួរដល់ផ្កា គួរដល់ផ្លែហើយ ក៏តែងបញ្ចេញផ្កាបញ្ចេញផ្លែ ក្នុង

សម័យដ៏ក្លៃ យ៉ាងណាមិញ, លោក ចូរបាននូវពោធិញ្ញាណដ៏ឧត្តម ដោយរួសរាន់ កុំកន្លងនូវសម័យដ៏ក្លៃនោះឡើយ ក៏យ៉ាងនោះដែរ ។ ពួកទេវតា លុះបានពោលសរសើរ ព្រមទាំងឲ្យពរសព្ទសាធុការដល់ពោធិសត្វយ៉ាងនេះហើយ ក៏វិលទៅកាន់ទេវស្ថានរបស់ខ្លួនៗ វិញ ។

ចំណែកខាងពោធិសត្វ លុះបានទទួលសេចក្ដីសរសើរមិនតិច អំពីទេវតាទាំងឡាយហើយក៏គិតថា អាត្មាអញនឹងបំពេញបារមីទាំង ១០ហើយ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងវេលាកាលកន្លងទៅអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ។ លុះគិតយ៉ាងនេះហើយ ក៏អធិដ្ឋាននូវព្យាយាមដ៏មាំ ហើយចូលឈានហោះហើរកាន់នភាល័យចូលទៅកាន់ព្រៃហិមពាន្តវិញ ។

ក៏កាលដែលព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករ បានព្យាករសរសើរសុមេធបណ្ឌិតជាអង្គពោធិសត្វរួចហើយ ទ្រង់បូជាពោធិសត្វដោយផ្កា ៨ ក្ដាប់ ហើយទ្រង់ប្រទក្សិណពោធិសត្វ រួចស្ដេចយាងចេញទៅ ។ ពួកភិក្ខុជាព្រះខីណាស្រពចំនួន ៤ សែនអង្គនេះ ក៏បានបូជាពោធិសត្វ ដោយផ្កាកម្រងនិងគ្រឿងក្រអូប ហើយដើរប្រទក្សិណ(១) និមន្តចេញទៅដែរ ។

---

១ ការដើរប្រទក្សិណ ជាទំនៀមទម្លាប់មួយរបស់អ្នកជម្ពូទ្វីប ឬ មជ្ឈិមប្រទេស រាប់ថាជាការសម្ដែងសេចក្ដីគោរព ឬ សេចក្ដីរាប់អានដ៏ខ្ពង់ខ្ពស់, មានតាំងពីព្រេងនាយ ដរាបមកដល់សម័យសព្វថ្ងៃនេះ ។ ក្នុងកម្ពុជរដ្ឋយើង មានប្រើប្រទក្សិណនេះដែរ ប៉ុន្តែប្រើមិនសព្វគ្រប់ដូចពួកមជ្ឈិមប្រទេសទេ ។

ចំណែកខាងមហាជនដែលនៅក្នុងក្រុងរម្មកៈ ទាំងប៉ុន្មាន បាននិមន្តព្រះសាស្តាព្រមទាំងភិក្ខុសង្ឃឲ្យចូលទៅក្នុងក្រុង ហើយថ្វាយមហាទានដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធានរួចស្រេចហើយ ព្រះបរមសាស្តាព្រះនាមទីបង្ករ ទ្រង់សំដែងធម៌ញុំាងមហាជនទាំងនោះ ឲ្យតាំងនៅក្នុងគុណមានសរណគមន៍ជាដើម ហើយទ្រង់ស្តេចចេញពីក្រុងរម្មកៈ តាមពុទ្ធអធ្យាស្រ័យ ។ តពីនោះ ទ្រង់ឋិតនៅតាមកំណត់ព្រះជន្មរបស់ព្រះអង្គ ទ្រង់បំពេញពុទ្ធកិច្ចទាំងពួងតាមលំដាប់លំដោយ រៀងរហូតដល់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។

ចប់ ទីបង្ករកថា ។

## ២– កោណ្ឌញ្ញកថា

ក្នុងអបរភាគកាល(១)នៃព្រះមានព្រះភាគ ព្រះនាមទីបង្ករបរិនិព្វានកន្លងទៅមួយអសង្ខេយ្យ, មានព្រះបរមសាស្តាព្រះនាម កោណ្ឌញ្ញៈ កើតឡើងក្នុងលោក ។ ព្រះពុទ្ធអង្គនោះ មានសាវកសន្និបាត ៣ លើក គឺ ក្នុងបឋមសន្និបាត មានភិក្ខុ ១ សែនកោដិ, ក្នុងទុតិយសន្និបាត មានភិក្ខុ ១ ពាន់កោដិ, ក្នុងតតិយសន្និបាត មានភិក្ខុ ៩០ កោដិ ។

គ្រានោះពោធិសត្វនៃយើង ជាស្តេចចក្រពត្តិទ្រង់ព្រះនាម វិជិតាវី

១ កាលជាចំណែកខាងក្រោយ ។

បានថ្វាយមហាទានដល់ភិក្ខុសង្ឃចំនួន ១ សែនកោដិ មានព្រះពុទ្ធជាប្រធាន ស្រេចហើយ ព្រះសាស្តាទ្រង់សម្តែងធម៌ព្យាករពោធិសត្វថា ព្រះករុណាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។ ព្រះមហាក្សត្រិយ៍អង្គនោះ លុះបានទ្រង់ព្រះសណ្តាប់ធម្មកថា នៃព្រះសាស្តាហើយ ក៏កើតសេចក្តីនឿយណាយ, លះរាជសម្បត្តិចេញទ្រង់ព្រះផ្នួស រៀនបិដកទាំង ៣ ចេះចប់, ហើយកាន់សេចក្តីព្យាយាមមាំ បានញុំាងឈាននិងអភិញ្ញាឲ្យកើតឡើង, ជាអ្នកមិនសាបសូន្យចាកឈាន, លុះដល់ទីបំផុតនៃជន្មាយុក៏បានទៅកើតក្នុងព្រហ្មលោក ។ ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈនោះ មាននគរឈ្មោះរម្មវតីជានិវេសនដ្ឋាន, ក្សត្រិយ៍ទ្រង់ព្រះនាមសុនន្ទ ជាព្រះពុទ្ធបិតា, ព្រះទេវីទ្រង់ព្រះនាមសុជាតា ជាព្រះពុទ្ធមាតា, ព្រះថេរៈឈ្មោះភទ្ទៈ និងព្រះថេរៈឈ្មោះសុភទ្ទៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះអនុរុទ្ធ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះតិស្សា និងព្រះថេរីឈ្មោះឧបតិស្សា ជាអគ្គសាវិកា, មានដើមសាលកល្យាណី (ដើមក្តៅនាង) ជាពោធិព្រឹក្ស, ព្រះសរីរៈរបស់ព្រះអង្គ កម្ពស់ ៨៨ ហត្ថ, ព្រះជន្មាយុរបស់ព្រះអង្គចំនួន ១ សែនឆ្នាំ ។

ចប់ កោណ្ឌញ្ញកថា ។

## ៣– មង្គលកថា

ក្នុងអបរភាគកាល នៃព្រះជានព្រះភាគព្រះនាមកោណ្ឌញ្ញៈនោះបរិនិព្វានកន្លងទៅមួយអសង្ខេយ្យ, មានព្រះពុទ្ធ ៤ ព្រះអង្គគឺ មង្គលៈ ១ សុមនៈ ១ រេវតៈ ១ សោភិតៈ ១ កើតឡើងក្នុងកប្បមួយជាមួយគ្នា(១) ។ ព្រះមានព្រះភាគព្រះនាម មង្គលៈ បានកើតឡើងក្នុងលោក មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុជាសាវក ១ សែនកោដិ, ក្នុងទុតិយសន្និបាត មានភិក្ខុជាសាវក ១ សែនកោដិ, ក្នុងតតិយសន្និបាត មានភិក្ខុជាសាវក ៩០ កោដិ ។

គ្រានោះ ពោធិសត្វនៃយើង កើតជាព្រាហ្មណ៍ឈ្មោះ សុរុចិ បាន

---

១ ព្រះសព្វញ្ញុពុទ្ធទាំង ៤ ព្រះអង្គនេះ មិនមែនបានត្រាស់ក្នុងកាលតែមួយទេ គឺមួយព្រះអង្គបានត្រាស់ដឹងឡើងហើយ ទ្រង់សម្តែងធម៌ប្រោសវេនេយ្យសត្វ គង់នៅរហូតដល់គំណត់ព្រះជន្មចូលបរិនិព្វានទៅ, ក្នុងកាលរៀងមក ទើបមួយព្រះអង្គបានត្រាស់ដឹងឡើងទៀត យ៉ាងនេះរហូតដល់គ្រប់ទាំង ៤ ព្រះអង្គ ព្រោះក្នុងកប្បនីមួយ ៗ កប្បខ្លះមានព្រះពុទ្ធបានត្រាស់ ១ ព្រះអង្គគត់ (កប្បនេះហៅថា សារកប្ប), កប្បខ្លះព្រះពុទ្ធបានត្រាស់ ២ ព្រះអង្គ (ហៅថា មណ្ឌកប្ប), កប្បខ្លះព្រះពុទ្ធបានត្រាស់ ៣ ព្រះអង្គ (ហៅថា វរកប្ប), កប្បខ្លះមានព្រះពុទ្ធត្រាស់ ៤ ព្រះអង្គ (ហៅថា សារមណ្ឌកប្ប), កប្បខ្លះដែលមានព្រះពុទ្ធត្រាស់ ៥ ព្រះអង្គ (ហៅថា ភទ្ទកប្ប ដូចកប្បបច្ចុប្បន្នយើងនេះ) ។ កប្បដែលមានព្រះពុទ្ធត្រាស់ ហៅថា អសុញ្ញកប្ប (កប្បមិនសូន្យ), កប្បដែលឥតមានព្រះពុទ្ធត្រាស់សោះ សូម្បីស្តេចចក្រពត្តិក៏មិនកើតសោះដែរ ហៅថា សុញ្ញកប្ប (កប្បសូន្យ) ។

ស្តាប់បតុរធម្មកថា នៃព្រះលោកនាយកព្រះនាមមង្គលៈនោះហើយ កើតសេចក្តីជ្រះថ្លា ក៏និមន្តព្រះពុទ្ធ ព្រមទាំងភិក្ខុសង្ឃមួយសែនកោដិ ឲ្យទទួលភិក្ខាហារនៅគេហដ្ឋានរបស់ខ្លួន ៗ, ព្រះបរមសាស្តាលុះធ្វើភត្តកិច្ចស្រេចហើយ ទ្រង់ធ្វើអនុមោទនាហើយទ្រង់ពិចារណាឃើញឧបនិស្ស័យថា បុរសនេះ បានធ្វើមហាទានមានសភាពយ៉ាងនេះ ចំណេរកាលទៅក្នុងអនាគត រាប់អំពីកប្បនេះទៅ នៅពីរអសង្ខេយ្យ និងមួយសែនកប្បទៀត នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គព្រះនាមគោតម ៗ មហាបុរសកាលបើបានស្តាប់ពុទ្ធព្យាករណ៍នោះហើយ គិតថា ប្រយោជន៍អ្វី ពេញអញនឹងនៅគ្រប់គ្រង់ផ្ទះ ហើយក៏លះបង់ទ្រព្យសម្បត្តិ ចេញទៅបួសក្នុងសំណាក់ព្រះបរមសាស្តា រៀនពុទ្ធវចនៈ បានញុំាងអភិញ្ញានិងសមាបត្តិឲ្យកើត, លុះដល់ទីបំផុតនៃអាយុ ក៏បានទៅកើតក្នុងព្រហ្មលោក ៗ

នគរជាលំនៅ នៃព្រះមានព្រះភាគព្រះនាមមង្គលៈនោះ ឈ្មោះឧត្តរៈ, ព្រះបិតាព្រះនាមឧត្តរៈ, ព្រះមាតាព្រះនាមឧត្តរា, ព្រះថេរៈឈ្មោះសុទេវៈ និងព្រះថេរៈឈ្មោះធម្មសេនៈ ជាអគ្គសាវក, ព្រះថេរៈឈ្មោះបាលិតៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះសិម្ពលី និងព្រះថេរីឈ្មោះអសោកា ជាអគ្គសាវិកា, ដើមនាគព្រឹក្ស (ដើមខ្លឹង) ជាពោធិ, ព្រះ

សរីរៈរបស់ព្រះអង្គ កម្ពស់ ៨៨ ហត្ថ, ព្រះអង្គទ្រង់គង់នៅអស់ ៩ ហ្មឺន ឆ្នាំ ទើបបរិនិព្វាន ។

ចប់ មង្គលកថា ។

## ៤– សុមនកថា

ក្នុងអបរភាគកាល នៃព្រះបាទព្រះភគវាព្រះនាមមង្គលៈនោះបរិនិព្វានកន្លងទៅហើយ បណ្តាលឲ្យងងឹតទាំងមួយហ្មឺនលោកធាតុ អស់កាលជាអន្ទូង ទើបព្រះបរមសាស្តាទ្រង់ព្រះនាម សុមនៈ កើតឡើងក្នុងលោក ។ ព្រះពុទ្ធអង្គនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុជាសាវកមួយសែនកោដិ, ក្នុងទុតិយសន្និបាត មានភិក្ខុជាសាវក ៩០ សែនកោដិ, ក្នុងតតិយសន្និបាត មានភិក្ខុជាសាវក ៨០ សែនកោដិ ។

គ្រានោះ ព្រះមហាសត្វនៃយើង កើតជានាគរាជឈ្មោះ អតុលៈ មានឫទ្ធិចិរានុភាពច្រើន កាលបានឮដំណឹងថា ព្រះពុទ្ធកើតឡើងហើយ ក៏នាំពួកព្រះញាតិជាបរិវារចេញអំពីភពនាគ ទៅច្រៀងប្រគំដោយតូរ្យតន្ត្រីថ្វាយព្រះបានព្រះភាគ ដែលមានភិក្ខុ ១ សែនកោដិជាបរិវារ រួចហើយក៏ថ្វាយសំពត់មួយគូ ៗ ផ្សេង ៗ គ្នា ហើយតាំងនៅក្នុងសរណគមន៍ផងទៀត ។ ព្រះបរមសាស្តាបានជ្រាបអធ្យាស្រ័យនៃនាគរាជនោះហើយ

ទ្រង់ព្យាករថា នាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ក្នុងអនាគត ។

ព្រះមានព្រះភាគព្រះនាមសុមនៈនោះ មាននគរឈ្មោះមេខលៈ ជានិវេសនដ្ឋាន, ព្រះរាជាព្រះនាមសុទត្តៈ ជាព្រះបិតា, ព្រះទេវីព្រះនាមសិរិមា ជាព្រះមាតា, ព្រះថេរៈពីរអង្គគឺ សរណត្ថេរ និង ភាវិតត្ថេរ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះឧទេនៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីពីរអង្គគឺ សោណាថេរី និងឧបសោណាថេរី ជាអគ្គសាវិកា, មាននាគព្រឹក្ស (ដើមរូង) ជាពោធិ, មានព្រះកាយកម្ពស់ ៩០ ហត្ថ, មានព្រះជន្មាយុ ៩ ហ្មឺនឆ្នាំ ។

ចប់ សុមនកថា ។

## ៥– រេវតកថា

ក្នុងអបរភាគកាលនៃព្រះលោកនាយកព្រះនាមសុមនៈនោះបរិនិព្វានកន្លងទៅហើយ ព្រះបរមសាស្តាទ្រង់ព្រះនាម រេវតៈ បានកើតឡើងក្នុងលោក ។ ព្រះសម្មាសម្ពុទ្ធអង្គនោះ មានសាវកសន្និបាត ៣ លើក គឺក្នុងបឋមសន្និបាតមិនមានការរាប់ចំនួនភិក្ខុ, ក្នុងទុតិយសន្និបាតមានភិក្ខុជាសាវ័កមួយសែនកោដិ, ក្នុងតតិយសន្និបាតក៏ដូចគ្នា ។ កាលនោះពោធិសត្វនៃយើងកើតជាព្រាហ្មណ៍ឈ្មោះ អតិទេវៈ បានស្តាប់ធម្មទេសនានៃព្រះសាស្តា ហើយតាំងនៅក្នុងសរណគមន៍និងសីល ហើយផ្គងអញ្ជលីលើសិរៈ ស្តាប់នូវសេចក្តីពណ៌នាសរសើរអំពីការលះកិលេស នៃព្រះសាស្តា

ក៏បានបួសជាព្រះអរហន្តដោយសំពត់បង់ក ។ ព្រះបរមគ្រូទ្រង់ព្យាករថា អតិទេវព្រាហ្មណ៍នេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គក្នុងអនាគត ។

នគរជាលំនៅនៃព្រះសម្មាសម្ពុទ្ធព្រះនាមរេវតៈនោះឈ្មោះសុធញ្ញវតី, ក្សត្រិយ៍ទ្រង់ព្រះនាមវិបុលៈ ជាព្រះបិតា, ព្រះទេវី ទ្រង់ព្រះនាមវិបុលា ជាព្រះមាតា, ព្រះថេរៈពីរអង្គគឺ វរុណត្ថេរ និងព្រហ្មទេវត្ថេរ ជាអគ្គសាវក, ព្រះថេរៈឈ្មោះសម្ភវៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីពីរអង្គគឺ ភទ្ទាថេរី និងសុភទ្ទាថេរី ជាអគ្គសាវិកា, មាននាគព្រឹក្ស (ដើមខ្ទឹង) ជាពោធិ, មានព្រះកាយខ្ពស់ ៨០ ហត្ថ, មានព្រះជន្មាយុ ៦ ហ្មឺនឆ្នាំ ។

ចប់ រេវតកថា ។

---

## ៦– សោភិតកថា

ក្នុងអបរភាគកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមរេវតៈនោះបរិនិព្វានកន្លងទៅហើយ ព្រះបរមសាស្ដាទ្រង់ព្រះនាម សោភិតៈ បានកើតឡើងក្នុងលោក, ព្រះអង្គមានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាតមានភិក្ខុ ១០០ កោដិ, ក្នុងទុតិយសន្និបាត មានភិក្ខុ ៩០ កោដិ, ក្នុងតតិយសន្និបាត មានភិក្ខុ ៨០ កោដិ ។ គ្រានោះ ពោធិសត្វនៃយើងកើតជាព្រាហ្មណ៍ឈ្មោះ អជិតៈ បានស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា, បានតាំងនៅក្នុងសរណគមន៍ ហើយបានថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះ

ពុទ្ធជាប្រធាន ។ ព្រះមានព្រះភាគទ្រង់ប្រថាប់អាស្រ័យអជិតព្រាហ្មណ៍នោះហើយ ទ្រង់ត្រាស់ថា ព្រាហ្មណ៍នេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។ ព្រះគោត្តមុនីព្រះនាមសោភិតៈនោះ មាននគរឈ្មោះសុធម្មៈ ជានិវេសនដ្ឋាន, ព្រះរាជាទ្រង់ព្រះនាមសុធម្មៈ ជាព្រះបិតា, ព្រះទេវីទ្រង់ព្រះនាមសុធម្មា ជាព្រះមាតា, ព្រះថេរៈឈ្មោះអសមៈ និងព្រះថេរៈឈ្មោះសុនេត្តៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះអនោមៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះនកុលា និងព្រះថេរីឈ្មោះសុជាតា ជាអគ្គសាវិកា, មាននាគព្រឹក្ស (ដើមខ្លឹម) ជាពោធិ, មានព្រះកាយកម្ពស់ ៥៨ ហត្ថ, មានព្រះជន្មាយុ ៩ ហ្មឺនឆ្នាំ ។

ចប់ សោភិតកថា ។

## ៧– អនោមទស្សិកថា

ក្នុងអបរភាគកាល នៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមសោភិតៈអង្គនោះបរិនិព្វានកន្លងទៅ អស់កាលមួយអសង្ខេយ្យ ទើបមានព្រះពុទ្ធ ៣ ព្រះអង្គ គឺ អនោមទស្សី ១ បទុមៈ ១ នារទៈ ១ កើតឡើង ក្នុងកប្បមួយជាមួយគ្នា ។ ព្រះពុទ្ធទ្រង់ព្រះនាម អនោមទស្សី មានសាវកសន្និបាត ៣ លើក គឺ ក្នុងបឋមសន្និបាត មានភិក្ខុ ៨ សែនអង្គ, ក្នុងទុតិយសន្និបាត មានភិក្ខុ ៧០ សែនអង្គ, ក្នុងតតិយសន្និបាត មានភិក្ខុ ៨ ហ្មឺន

៦ ពាន់កោដិ ។ គ្រានោះពោធិសត្វនៃយើង ជាសេនាបតីនៃយក្សមួយមានឫទ្ធិ និងអានុភាពដ៏ធំ ជាអធិបតីនៃយក្សទាំងឡាយច្រើនសែនកោដិ ។ យក្សសេនាបតីនោះ បានឮដំណឹងថាព្រះពុទ្ធកើតឡើងហើយ ក៏បានសេចក្ដីជ្រះថ្លា បានមកធ្វើសក្ការបូជា ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះបរមសាស្ដាទ្រង់ព្យាករថា យក្សសេនាបតីនេះ នឹងបានជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។ ព្រះមានព្រះភាគព្រះនាមអនោមទស្សីនោះ មាននគរឈ្មោះចន្ទវតីជានិវេសនដ្ឋាន, ព្រះរាជាទ្រង់ព្រះនាមយសវ ជាព្រះបិតា, ព្រះទេវីទ្រង់ព្រះនាមយសោធរា ជាព្រះមាតា, ព្រះថេរៈឈ្មោះនិសភៈ និងព្រះថេរៈឈ្មោះអនោមៈ ជាអគ្គសាវក, ព្រះថេរៈឈ្មោះវរុណៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះសុន្ទរី និងព្រះថេរីឈ្មោះសុមនា ជាអគ្គសាវិកា, មានអជ្ជុនព្រឹក្ស(១) (ដើមថ្កាន់) ជាពោធិ, មានព្រះកាយខ្ពស់ ៥៨ ហត្ថ, មានព្រះជន្មាយុមួយសែនឆ្នាំ ។

ចប់ អនោមទស្សីកថា ។

## ៨- បទុមកថា

ក្នុងអបរភាគកាលនៃព្រះពុទ្ធព្រះនាមអនោមទស្សីអង្គនោះបរិនិព្វាន

១ ក្នុងអភិធានប្បទីបិកានិងអដ្ឋកថាប្រើពាក្យថា អជ្ជុន និង កកុធ ជាឈ្មោះឈើតែមួយប្រភេទជាមួយគ្នា, កកុធ ប្រែថា "ដើមថ្កាន់" អជ្ជុន ក៏ថា "ថ្កាន់" ដែរ ប៉ុន្តែ អជ្ជុន លោកអ្នកប្រាជ្ញខ្លះយល់ថា "ដើមឈ្មឹក" វិញ ។

កន្លងទៅហើយ ទើបមានព្រះសម្មាសម្ពុទ្ធព្រះនាមបទុមៈ កើតឡើងក្នុងលោក ។ ព្រះសព្វញ្ញុពុទ្ធអង្គនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុមួយសែនកោដិអង្គ, ក្នុងទុតិយសន្និបាត មានភិក្ខុបីសែនអង្គ,. ក្នុងតតិយសន្និបាត បានភិក្ខុពីរសែនអង្គ ប្រជុំក្នុងដងព្រៃមហាវ័ន ។ កាលនោះ ពោធិសត្វនៃយើង កើតជាសត្វសីហៈ បានឃើញព្រះសាស្ដាកំពុងចូលនិរោធសមាបត្តិ ក្នុងមហាវ័ននោះ ក៏មានចិត្តជ្រះថ្លា បានថ្វាយបង្គំ ដើរប្រទក្សិណ មានបីតិនិងសោមនស្សកើតឡើងបន្លឺសីហនាទអស់វារៈ ៣ ដង ដោយអំណាចសុខដែលកើតអំពីបីតិ និងសេចក្ដីជ្រះថ្លាចំពោះព្រះពុទ្ធ មិនចេញទៅស្វែងរកអាហារអស់ ៧ ថ្ងៃ ស៊ូប្រថុយលះបង់ជីវិត ចូលទៅគាល់ជិតព្រះអង្គ ។ លុះកន្លងផុត ៧ ថ្ងៃទៅ ព្រះបរមសាស្ដាទ្រង់ចេញចាកនិរោធសមាបត្តិហើយ ទតទៅឃើញសត្វសីហៈកំពុងញុំាងចិត្តឲ្យជ្រះថ្លា ចំពោះព្រះអង្គនិងភិក្ខុសង្ឃផងឡាយ ក៏ទ្រង់ព្យាករថា សីហៈនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។ ព្រះមានព្រះភាគព្រះនាមបទុមៈនោះ មាននគរឈ្មោះចម្បកៈ ជានិវេសនដ្ឋាន, ព្រះរាជាទ្រង់ព្រះនាមបទុមៈ ជាព្រះបិតា, ព្រះទេវីទ្រង់ព្រះនាមអសមា ជាព្រះមាតា, ព្រះថេរៈឈ្មោះសាលៈ និងព្រះថេរៈឈ្មោះឧបសាលៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះវរុណៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរី

ឈ្មោះរាធា និងព្រះថេរីឈ្មោះសុរាធា ជាអគ្គសាវិកា, មានសោណព្រឹក្ស (ដើមភេគា) ជាពោធិ, មានព្រះកាយកម្ពស់ ៥៨ ហត្ថ, មានព្រះជន្មាយុ មួយសែនឆ្នាំ ។

ចប់ បទុមកថា ។

## ៩– នារទកថា

ក្នុងអបរភាគកាល នៃព្រះសព្វញ្ញុពុទ្ធទ្រង់ព្រះនាមបទុមៈនោះ បរិនិព្វានកន្លងទៅហើយ ទើបព្រះបរមសាស្ដាព្រះនាមនារទៈ កើតឡើងក្នុងលោក ។ ព្រះសម្មាសម្ពុទ្ធអង្គនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុ ១ សែនកោដិ, ក្នុងទុតិយសន្និបាត មានភិក្ខុ ៩០ សែនកោដិ, ក្នុងតតិយសន្និបាត មានភិក្ខុ ៨០ សែនកោដិ ។ គ្រានោះ ពោធិសត្វនៃយើងបួសជាតាបស ជាអ្នកមានសេចក្ដីស្ទាត់ជំនាញក្នុងអភិញ្ញា ៥ និងសមាបត្តិ ៨ បានឲ្យមហាទាន ព្រមទាំងបានបូជាខ្លឹមចន្ទន៍ក្រហម ដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះបរមលោកនាថ ទ្រង់ជ្រាបនូវវារៈនៃចិត្តតាបសនោះហើយ ទ្រង់ព្យាករថា តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមនារទៈនោះ

មាននគរឈ្មោះធញ្ញវតី ជានិវេសនដ្ឋាន, ក្សត្រិយ៍ទ្រង់ព្រះនាមសុមេធៈ ជាព្រះបិតា, ព្រះទេវីទ្រង់ព្រះនាមអនោមា ជាព្រះមាតា, ព្រះថេរៈឈ្មោះវាសេដ្ឋៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះឧត្តរា និងព្រះថេរីឈ្មោះផគ្គុណី ជាអគ្គសាវិកា; មានមហាសោណព្រឹក្ស (ដើមកេកាយ៉ាងធំ) ជាពោធិ, មានព្រះកាយកម្ពស់ ៨៨ ហត្ថ, មានព្រះជន្មាយុ ៩ ហ្មឺនឆ្នាំ ។

ចប់ នារទកថា ។

## ១០- បទុមុត្តរកថា

ក្នុងអបរភាគកាល នៃព្រះពុទ្ធព្រះនាមនារទៈនោះបរិនិព្វានកន្លងទៅហើយ បានមួយអសង្ខេយ្យ និងមួយសែនកប្ប ទើបព្រះពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈកើតឡើងក្នុងកប្បមួយៗ ព្រះសម្មាសម្ពុទ្ធអង្គនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុ ១ សែនកោដិ, ក្នុងទុតិយសន្និបាត មានភិក្ខុ ៩០ សែនកោដិ ប្រជុំគ្នាលើវេភារបព៌ត, ក្នុងតតិយសន្និបាត មានភិក្ខុ ៨ ហ្មឺនកោដិ ។ គ្រានោះពោធិសត្វនៃយើងជា មហារដ្ឋិយជដិល បានថ្វាយចីវរទានដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះមានព្រះភាគទ្រង់ព្យាករថា ជដិលនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។ នគររបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈនោះ ឈ្មោះហំសវតី, ព្រះបិតា ជាក្សត្រិយ៍ទ្រង់ព្រះនាមអានន្ទ, ព្រះមាតា ទ្រង់ព្រះនាមសុជាតា,

*ព្រះថេរៈឈ្មោះទេវលៈ និងព្រះថេរៈឈ្មោះសុជាតៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះសុមនៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះអមិតា និងព្រះថេរីឈ្មោះអសមា ជាអគ្គសាវិកា, មានសាលព្រឹក្ស(១) ជាពោធិ, មានព្រះកាយកម្ពស់ ៨៨ ហត្ថ, មានរស្មីផ្សាយចេញអំពីសរីរៈ ១២ យោជន៍ជុំវិញ, មានព្រះជន្មាយុចំនួនមួយសែនឆ្នាំ ។*

ចប់ បទុមុត្តរកថា ។

## ១១- សុមេធកថា

*ក្នុងបរោគកាល នៃព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈនោះបរិនិព្វានកន្លង*

---

១ សាលព្រឹក្ស យើងធ្លាប់យល់បកប្រែហើយថា "ដើមរាំងភ្នំ", តាមពិតមិនមែនរាំងភ្នំទេ, ជាឈ្មោះឈើមួយប្រភេទ មានស្លឹកស្តើងកាត់ប្រវែងចន្លោះមរវែង ៗ មានត្រួយទុំ, ជាឈើធំមានឫសល្អ មានផ្កាធំ ៗ ទងវែង ៗ ចេញពីដើម មានសម្បុរស្រអៀតនឹងផ្កាល្មូកប្រហែល មានក្លិនក្រអូបឈ្ងុយ ផ្លូវក្លិនទឹកអប់មួយប្រភេទ, ផ្លែស្រដៀងនឹងផ្លែព្រៅ ប៉ុន្តែធំជាងព្រៅបន្តិច ។ ល ។ កាលពី ព. ស. ២៤៩៣ គ. ស. ១៩៥០ សម្តេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណ ជ. ណ.) បានព្យាយាមយកកូនសាលព្រឹក្សនេះ ៨ ដើមពីលង្កាទ្វីបមក ។ ល ។ បានឲ្យដាំពីរដើមខាងមុខបញ្ចាំងបុរាណកុដិធំខាងជើងព្រះវិហារវត្តឧណ្ណាលោម ។ ក្នុងអភិធានប្បទីបិកា និងអដ្ឋកថាច្រើនអធិប្បាយថា សាលព្រឹក្សនេះ ហៅថា អស្សកណ្ណព្រឹក្ស "ដើមត្រចៀកសេះ" ក៏បាន, បណ្ឌិតក្នុងកម្ពុជរដ្ឋ ប្រែថា ដើមត្រចៀកប្រើស ។ ព្រះសក្យមុនីសម្ពុទ្ធជាបរមគ្រូរបស់យើង ទ្រង់ប្រសូត ទ្រង់ចូលបរិនិព្វាន ក្រោមដើមសាលព្រឹក្ស ឬដើមអស្សកណ្ណព្រឹក្សនេះ ។

ទៅហើយបាន ៣. ហ្មឺនកប្ប. ទើបព្រះពុទ្ធពីរព្រះអង្គគឺ ព្រះពុទ្ធទ្រង់ព្រះនាមសុមេធៈ ១ ព្រះពុទ្ធទ្រង់ព្រះនាមសុជាតៈ ១ កើតឡើងក្នុងកប្បមួយជាមួយគ្នា ។ ឯព្រះពុទ្ធទ្រង់ព្រះនាមសុមេធៈ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុជាព្រះខីណាស្រព មួយរយកោដិប្រជុំក្នុងសុទស្សននគរ, ក្នុងទុតិយសន្និបាត មានភិក្ខុ ៩០ កោដិ, ក្នុងតតិយសន្និបាត មានភិក្ខុ ៨០ កោដិ ។ គ្រានោះ ពោធិសត្វនៃយើងជាមាណពឈ្មោះឧត្តរៈ បានបំណាយទ្រព្យដែលខ្លួនរប់ទុកក្នុងផែនដី ថ្វាយជាមហាទានដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន, បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ ក៏ចៀសណាយក្នុងកាយ ចេញបួសក្នុងសម្នាក់ព្រះសព្វញ្ញុពុទ្ធ, ព្រះអង្គទ្រង់ព្យាករថា ឧត្តរមាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គ ក្នុងអនាគត ។

នគររបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមសុមេធៈនោះ ឈ្មោះសុទស្សនៈ, ព្រះវរពុទ្ធបិតាព្រះនាមសុទត្តៈ, ព្រះវរពុទ្ធមាតាព្រះនាមសុទត្តា, ព្រះថេរៈឈ្មោះសុមនៈ និងព្រះថេរៈឈ្មោះសព្វកាមៈ ជាអគ្គសាវក, ព្រះថេរៈឈ្មោះសាគរៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះរាមា និងព្រះថេរីឈ្មោះសុរាមា ជាអគ្គសាវិកា, មានមហានិម្ពព្រឹក្ស (ដើមស្តៅយ៉ាងធំ) ជាពោធិ, មានព្រះកាយកម្ពស់ ៨៨ ហត្ថ, មានព្រះជន្មាយុ ៩ ហ្មឺនឆ្នាំ ។

ចប់ សុមេធកថា ។

## ១២– សុជាតកថា

ក្នុងអបរភាគកាល នៃព្រះពុទ្ធទ្រង់ព្រះនាមសុមេធៈនោះ បរិនិព្វាន កន្លងទៅហើយ ទើបព្រះពុទ្ធទ្រង់ព្រះនាមសុជាតៈកើតឡើងក្នុងលោកៗ ព្រះមានព្រះភាគព្រះនាមសុជាតៈនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុ ៦ ហ្មឺនរូប, ក្នុងទុតិយសន្និបាត មានភិក្ខុ ៥០ រូប, ក្នុងតតិយសន្និបាត មានភិក្ខុ ៤០ រូប ។

គ្រានោះ ពោធិសត្វនៃយើងជាស្ដេចចក្រពត្តិ ទ្រង់បានជ្រាបដំណឹងថា ព្រះពុទ្ធកើតឡើងហើយ ក៏ចូលទៅគាល់ ទ្រង់ព្រះសណ្ដាប់ព្រះធម្មទេសនា ហើយបានថ្វាយរាជសម្បត្តិក្នុងទ្វីបធំទាំង ៤ មួយអន្លើដោយកែវទាំង ៧ ដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ហើយចេញទ្រង់ព្រះផ្នួសក្នុងសម្នាក់ព្រះសាស្ដា ។ ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករថា ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។ នគររបស់ព្រះមានព្រះភាគទ្រង់ព្រះនាមសុជាតៈនោះ ឈ្មោះសុមង្គលៈ, ព្រះរាជបិតាព្រះនាមឧគ្គតៈ, ព្រះរាជមាតា ព្រះនាមបភាវតី, ព្រះថេរៈឈ្មោះសុទស្សនៈ និងព្រះថេរៈឈ្មោះសុទេវៈ ជាអគ្គសាវក, ព្រះថេរៈឈ្មោះនារទៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះនាគា និងព្រះថេរីឈ្មោះនាគសមាលា

ជាអគ្គសាវិកា, មានមហាវេឡុព្រឹក្ស (ឫស្សីធំ) ជាពោធិ, មានព្រះកាយកម្ពស់ ៥០ ហត្ថ, មានព្រះជន្មាយុ ៩ ហ្មឺនឆ្នាំ ។

ចប់ សុជាតកថា ។

## ១៣– បិយទស្សីកថា

ក្នុងអបរភាគកាល នៃព្រះពុទ្ធទ្រង់ព្រះនាមសុជាតៈនោះបរិនិព្វានកន្លងទៅហើយ ទើបមានព្រះពុទ្ធ ៣ ព្រះអង្គគឺ ព្រះបិយទស្សី ១, ព្រះអត្ថទស្សី ១ ព្រះធម្មទស្សី ១ កើតឡើងក្នុងកប្បមួយជាមួយគ្នា រាប់ថយក្រោយអំពីភទ្ទកប្បនេះទៅ ១៩ កប្ប ។ ឯព្រះពុទ្ធបិយទស្សីនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុ ១ សែនកោដិ, ក្នុងទុតិយសន្និបាត មានភិក្ខុ ៩០ កោដិ, ក្នុងតតិយសន្និបាត មានភិក្ខុ ៨០ កោដិ ។ គ្រានោះ ពោធិសត្វនៃយើងជាមាណពឈ្មោះកស្សបៈ ជាអ្នកចេះចាំនូវត្រៃវេទ បានស្តាប់ព្រះធម្មទេសនានៃព្រះសាស្តា ហើយបរិច្ចាគទ្រព្យមួយសែនកោដិ កសាងអារាម ប្រគេនព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ហើយតាំងនៅក្នុងសរណគមន៍និងសីល ។ លំដាប់នោះ ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករថា កស្សបមាណពនេះ ចំណេរកាលទៅឯអនាគតរាប់ពីត្រឹមកប្បនេះតទៅ ១៨ កប្បទៀត នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គ ។ នគរ

របស់ព្រះមានព្រះភាគទ្រង់ព្រះនាមបិយទស្សីនោះ ឈ្មោះអនោមៈ, ព្រះរាជបិតា ព្រះនាមសុទិន្នៈ, ព្រះរាជមាតា ព្រះនាមចន្ទា, ព្រះថេរៈឈ្មោះបាលិតៈ និងព្រះថេរៈឈ្មោះសព្វទស្សី ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះសោភិតៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះសុជាតា និងព្រះថេរីឈ្មោះធម្មទិន្នា ជាអគ្គសាវិកា, មានកកុធព្រឹក្ស ( ដើមថ្ងាន់ ) ជាពោធិ, មានព្រះកាយកម្ពស់ ៨០ ហត្ថ, មានព្រះជន្មាយុចំនួន ៩ ហ្មឺនឆ្នាំ ។

ចប់ បិយទស្សីកថា ។

## ១៤– អត្ថទស្សីកថា

ក្នុងអបរភាគកាល នៃព្រះពុទ្ធទ្រង់ព្រះនាមបិយទស្សីនោះ បរិនិព្វានកន្លងទៅហើយ ទើបមានព្រះពុទ្ធទ្រង់ព្រះនាមអត្ថទស្សី កើតឡើង ក្នុងលោក ។ ព្រះពុទ្ធអង្គនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុ ៩៨ សែនរូប, ក្នុងទុតិយសន្និបាត មានភិក្ខុ ៨ សែនរូប, ក្នុងតតិយសន្និបាត ក៏ដូចគ្នា ។

គ្រានោះ ពោធិសត្វនៃយើង ជាបុរសឈ្មោះសុសិមៈ បួសជាតាបសមានឫទ្ធិច្រើន បានទៅនាំយកផ្កាមន្ទារវបុស្សអំពីឋានទេវលោក មកធ្វើជាឆត្របូជាព្រះសាស្តា ។ ព្រះសម្ពុទ្ធទ្រង់ព្យាករថា តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។ នគររបស់ព្រះមានព្រះភាគ

ទ្រង់ព្រះនាមអត្ថទស្សីនោះ ឈ្មោះសោភិតៈ, ព្រះវររាជបិតា ព្រះនាមសាគរៈ, ព្រះវររាជមាតា ព្រះនាមសុទស្សនា, ព្រះថេរៈឈ្មោះសន្តៈ និងព្រះថេរៈឈ្មោះឧបសន្តៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះអភយៈ ជាពុទ្ធុ-បដ្ឋាក, ព្រះថេរីឈ្មោះធម្មា និងព្រះថេរីឈ្មោះសុធម្មា ជាអគ្គសាវិកា, មានចម្បកព្រឹក្ស ( ដើមចម្បក ) ជាពោធិ, មានព្រះកាយកម្ពស់ ៨៨ ហត្ថ, មានរស្មីផ្សាយចេញអំពីព្រះសរីរៈប្រមាណមួយយោជន៍ជុំវិញ អស់កាលជានិច្ច, មានព្រះជន្មាយុចំនួនមួយសែនឆ្នាំ ។

ចប់ អត្ថទស្សីកថា ។

## ១៥– ធម្មទស្សីកថា

ក្នុងអបរភាគកាល នៃព្រះពុទ្ធទ្រង់ព្រះនាមអត្ថទស្សីនោះបរិនិព្វានកន្លងទៅហើយ ទើបព្រះពុទ្ធទ្រង់ព្រះនាមធម្មទស្សី កើតឡើងក្នុងលោក ។ ព្រះសម្មាសម្ពុទ្ធអង្គនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុមួយរយកោដិ, ក្នុងទុតិយសន្និបាត មានភិក្ខុ ៧០ កោដិ, ក្នុងតតិយសន្និបាត មានភិក្ខុ ៨០ កោដិ ។ គ្រានោះ ពោធិសត្វនៃយើងជាស្ដេចនៃទេវតាឈ្មោះសក្កៈ ( ព្រះឥន្ទ្រ ) បានបូជាព្រះសាស្ដា ដោយផ្កាមានក្លិនក្រអូបជាទិព្វផង ដោយតូរ្យតន្ត្រីជាទិព្វផង ហើយព្រះ

សព្វញ្ញុពុទ្ធទ្រង់ព្យាករថា សក្កទេវរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ៗ នគររបស់ព្រះមានព្រះភាគទ្រង់ព្រះនាមធម្មទស្សីនោះឈ្មោះសរណៈ, ព្រះវររាជបិតា ព្រះនាមសរណៈ, ព្រះវររាជមាតា ព្រះនាមសុនន្ទា, ព្រះថេរៈឈ្មោះបទុមៈ និងព្រះថេរៈឈ្មោះបុស្សទេវៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះសុនេត្តៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះខេមា និងព្រះថេរីឈ្មោះសព្វនាមា ជាអគ្គសាវិកា, មានរត្តកុរវកព្រឹក្ស ( ដើមឈើក្រើង ) ជាពោធិ, មានព្រះកាយកម្ពស់ ៨០ ហត្ថ មានព្រះជន្មាយុចំនួនមួយសែនឆ្នាំ ៗ

ចប់ ធម្មទស្សីកថា ។

## ១៦– សិទ្ធត្ថកថា

ក្នុងបរភាគកាល នៃព្រះពុទ្ធទ្រង់ព្រះនាមធម្មទស្សីនោះបរិនិព្វានកន្លងទៅហើយ ទើបមានព្រះពុទ្ធមួយអង្គទ្រង់ព្រះនាមសិទ្ធត្ថៈ កើតឡើងក្នុងកប្ប ១ ៗ ព្រះសម្មាសម្ពុទ្ធអង្គនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុមួយរយកោដិ, ក្នុងទុតិយសន្និបាតមានភិក្ខុ ៩០ កោដិ, ក្នុងតតិយសន្និបាត មានភិក្ខុ ៨០ កោដិ ៗ គ្រានោះ ពោធិសត្វនៃយើង ជាបុរសឈ្មោះមង្គលៈ បួសជាតាបសមានតេជះដ៏ខ្ពង់ខ្ពស់ បរិបូណ៌ដោយអភិញ្ញាពល បានទៅនាំយកផ្លែព្រីងធំមកថ្វាយ

ព្រះមានព្រះភាគ, ព្រះអង្គទទួលសោយផ្លែព្រីងនោះហើយ ទ្រង់ធ្វើអនុ-មោទនាព្យាករពោធិសត្វថា រាប់ពីត្រឹមកប្បនេះទៅ នៅ ៩៤ កប្បទៀត ខ្លួនអ្នកនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។ នគររបស់ព្រះពុទ្ធទ្រង់ព្រះនាមសិទ្ធត្ថៈនោះ ឈ្មោះវេភារៈ, ព្រះវរបិតា ព្រះនាមជយសេន, ព្រះវរមាតា ព្រះនាមសុផស្សា, ព្រះថេរៈឈ្មោះសម្ពលៈ និងព្រះថេរៈឈ្មោះសុមិត្តៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះរេវតៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះ សិវលា និងព្រះថេរីឈ្មោះ សុរាមា ជាអគ្គសាវិកា, ដើមកណ្ណិកាព្រឹក្ស ( ដើមកណ្ណិកា ) ជាពោធិ, មានព្រះកាយកម្ពស់ ៦០ ហត្ថ, មានព្រះជន្មាយុចំនួនមួយសែនឆ្នាំ ។

ចប់ សិទ្ធត្ថកថា ។

## ១៧– តិស្សកថា

ក្នុងអបរភាគកាល នៃព្រះពុទ្ធទ្រង់ព្រះនាមសិទ្ធត្ថៈនោះបរិនិព្វានក្នុងទៅហើយ រាប់ថយក្រោយអំពីកប្បនេះទៅបាន ៩២ កប្ប មានព្រះពុទ្ធពីរព្រះអង្គគឺ ព្រះពុទ្ធព្រះនាមតិស្សៈ ១ ព្រះពុទ្ធព្រះនាមផុស្សៈ ១ កើតឡើងក្នុងកប្បមួយជាមួយគ្នា ។ ព្រះពុទ្ធទ្រង់ព្រះនាមតិស្សៈ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុមួយរយកោដិ, ក្នុងទុតិយសន្និបាត មានភិក្ខុ ៩០ កោដិ, ក្នុងតតិយសន្និបាត មានភិក្ខុ ៨០

កោដិ ។ គ្រានោះ ពោធិសត្វនៃយើង ជាព្រះរាជាទ្រង់ព្រះនាមសុជាតៈមាន ភោគៈ និងយសដ៏ធំ បានលះបង់រាជសម្បត្តិ ចេញទ្រង់ព្រះផ្នួសជាតាបស ឫសី ជាអ្នកមានឫទ្ធិច្រើន, ថ្ងៃមួយ ពោធិសត្វបានឮដំណឹងថា ព្រះពុទ្ធ កើតឡើងហើយ ក៏នាំយកផ្កាមន្ទារវបុស្ស, ផ្កាឈូក និងផ្កាបារិច្ឆត្តក-ព្រឹក្សដ៏ជាទិព្វ ទៅបូជាព្រះតថាគត ដែលកំពុងគង់ក្នុងកណ្ដាលបរិស័ទ ទាំង ៤ ហើយយកផ្កាខ្លះ ធ្វើជាពិតាន បាំងតថាគតក្នុងអាកាសថែម ទៀត ។ ព្រះសាស្ដាទ្រង់ព្យាករថា តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធ មួយអង្គក្នុងអនាគត អំពី ៩២ កប្បពីកប្បនេះទៅ ។ នគររបស់ព្រះពុទ្ធ ទ្រង់ព្រះនាមតិស្សៈនោះ ឈ្មោះខេមៈ, ព្រះវររាជបិតា ព្រះនាមជនសន្ធៈ; ព្រះវររាជមាតា ព្រះនាមបទុមា, ព្រះថេរៈឈ្មោះព្រហ្មទេវៈ និងព្រះថេរៈ ឈ្មោះឧទយៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះសម្ភវៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះបុស្សា និងព្រះថេរីឈ្មោះសុទត្តា ជាអគ្គសាវិកា, មានអសន-ព្រឹក្ស ( ដើមផ្គង់ ) ជាពោធិ, មានព្រះកាយកម្ពស់ ៦០ ហត្ថ, មានព្រះជន្មាយុប្រមាណមួយសែនឆ្នាំ ។

ចប់ តិស្សកថា ។

---

## ១៨- ផុស្សកថា

ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធទ្រង់ព្រះនាមតិស្សៈនោះបរិនិព្វាន

កន្លងទៅហើយ ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈ(១)កើតឡើងក្នុងលោក ។ ព្រះមានព្រះភាគអង្គនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុ ៦០ សែនរូប, ក្នុងទុតិយសន្និបាត មានភិក្ខុ ៥០ សែនរូប, ក្នុងតតិយសន្និបាត មានភិក្ខុ ៣២ សែនរូប ។ គ្រានោះ ពោធិសត្វនៃយើង ជាក្សត្រិយ៍សោយរាជ្យទ្រង់ព្រះនាមវិជិតាវី បានលះបង់មហារាជសម្បត្តិ ហើយចេញទ្រង់ព្រះផ្នួសជាភិក្ខុ ក្នុងសម្នាក់ព្រះសាស្តា រៀនព្រះត្រៃបិដកចេះចាំ ហើយសម្តែងធម្មកថាដល់មហាជនផង បំពេញនូវសីលបារមីផង ។ ចំណែកខាងព្រះមានព្រះភាគទ្រង់ព្យាករថា ភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគត ។

នគររបស់ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈនោះ ឈ្មោះកាសី, ព្រះរាជបិតា ព្រះនាមជយសេន, ព្រះរាជមាតា ព្រះនាមសិរិមា, ព្រះថេរៈឈ្មោះសុរក្ខិតៈ និងព្រះថេរៈឈ្មោះជយសេន ជាអគ្គសាវក, ព្រះថេរៈឈ្មោះសោភិយៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះចាលា និងព្រះថេរីឈ្មោះឧបចាលា ជាអគ្គសាវិកា, មានអាមលកព្រឹក្ស (ដើមកន្ទួតព្រៃ) ជាពោធិ, មានព្រះកាយកម្ពស់ ៥៨ ហត្ថ, មានព្រះជន្មាយុប្រមាណ ៩ ហ្មឺនឆ្នាំ ។

១ ផុស្សៈ ក៏អាន ។

ចប់ ផុស្សកថា ។

# ១៩– វិបស្សីកថា

ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈនោះ បរិនិព្វាន កន្លងទៅហើយ ទើបព្រះមានព្រះភាគព្រះនាម វិបស្សី កើតឡើង ក្នុងលោក ។ ព្រះសម្មាសម្ពុទ្ធនោះ មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុ ៦៨ សែនរូប, ក្នុងទុតិយសន្និបាត មានភិក្ខុ៩១ សែនរូប, ក្នុងតតិយសន្និបាតមានភិក្ខុ ៨ ហ្មឺនរូប ។ គ្រានោះ ពោធិសត្វនៃយើងជានាគរាជឈ្មោះអតុលៈ មានឫទ្ធិនិងអានុភាពដ៏ធំ បានថ្វាយតាំង ជាវិការៈនៃមហាសផលវិចិត្រដោយកែវ ៧ ប្រការ ដល់ព្រះមានព្រះភាគ ។ ទ្រង់ព្យាករថា នាគរាជនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គ ក្នុងពេល ៩១ កប្ប រាប់អំពីកប្បនេះទៅ ។ នគររបស់ព្រះពុទ្ធទ្រង់ព្រះនាមវិបស្សីនោះ ឈ្មោះពន្ធុមតី, ព្រះរាជបិតា ទ្រង់ព្រះនាមពន្ធុមា; ព្រះរាជមាតា ទ្រង់ព្រះនាមពន្ធុមតី, ព្រះថេរៈឈ្មោះខណ្ឌៈ និងព្រះថេរៈឈ្មោះតិស្សៈ ជាអគ្គសាវក, ព្រះថេរៈឈ្មោះអសោក ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះចន្ទា និងព្រះថេរីឈ្មោះចន្ទមិត្តា ជាអគ្គសាវិកា, មានបាដលិព្រឹក្ស (ដើមជ្រនៀង) ជាពោធិ, មានព្រះកាយខ្ពស់ ៨០ ហត្ថ, មានរស្មីផ្សាយចេញអំពីព្រះកាយ ៧ យោជន៍ជុំវិញ, មានព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ ។

ចប់ វិបស្សីកថា ។

## ២០– សិខិកថា

ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធទ្រង់ព្រះនាមវិបស្សីនោះបរិនិព្វានកន្លងទៅហើយ មានព្រះពុទ្ធពីរព្រះអង្គ គឺព្រះពុទ្ធទ្រង់ព្រះនាមសិខី ១ ព្រះពុទ្ធទ្រង់ព្រះនាមវេស្សភូ ១ កើតឡើងក្នុងរវាង ៣១ កប្ប រាប់ថយក្រោយអំពីកប្បនេះទៅ ។ ព្រះពុទ្ធទ្រង់ព្រះនាមសិខី មានសាវកសន្និបាត ៣ លើកគឺ ក្នុងបឋមសន្និបាត មានភិក្ខុមួយសែនរូប, ក្នុងទុតិយសន្និបាត មានភិក្ខុ ៨ ពាន់រូប, ក្នុងតតិយសន្និបាត មានភិក្ខុ ៧ ពាន់រូប ។ គ្រានោះ ព្រះពោធិសត្វនៃយើងសោយរាជ្យជាស្តេច ទ្រង់ព្រះនាមអរិន្ទម: បានថ្វាយមហាទានមានចីវរទានជាដើម ព្រមទាំងថ្វាយដំរីកែវប្រដាប់ដោយកែវ ៧ ប្រការដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន, មិនត្រឹមតែប៉ុណ្ណោះ, បានតាំងថ្វាយកប្បិយភណ្ឌ ដល់ព្រះសម្មាសម្ពុទ្ធថែមទៀត ។ ព្រះសាស្តាទ្រង់ព្យាករថា ព្រះរាជាអង្គនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងរវាង ៣១ កប្ប រាប់អំពីកប្បនេះទៅ ។ នគររបស់ព្រះពុទ្ធទ្រង់ព្រះនាមសិខីនោះឈ្មោះអរុណវតី, ព្រះវររាជបិតាព្រះនាមអរុណ:, ព្រះវររាជមាតាព្រះនាមបភាវតី, ព្រះថេរៈឈ្មោះអភិភូ និងព្រះថេរៈឈ្មោះសម្ភវៈ ជាអគ្គសាវក, ព្រះថេរៈឈ្មោះខេមង្ករៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះខេមា និងព្រះថេរីឈ្មោះបទុមា ជាអគ្គសាវិកា, មានបុណ្ឌរីកព្រឹក្ស

(ដើមស្វាយ-ស) ជាពោធិ, មានព្រះកាយខ្ពស់ ៣៧ ហត្ថ, មានរស្មីផ្សាយចេញអំពីព្រះសរីរៈ ៣ យោជន៍ជុំវិញ, មានព្រះជន្មាយុប្រមាណ ៣ ហ្មឺន ៧ ពាន់ឆ្នាំ ។

ចប់ សិខិកថា ។

## ២១-វេស្សភូកថា

ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធទ្រង់ព្រះនាមសិខីនោះ បរិនិព្វានកន្លងទៅហើយ ទើបព្រះសាស្តាព្រះនាមវេស្សភូកើតឡើងក្នុងលោក ។ ព្រះសាស្តាអង្គនោះ មានសាវកសន្និបាត ៣ លើក គឺ ក្នុងបឋមសន្និបាត មានភិក្ខុ ៨០ សែនរូប, ក្នុងទុតិយសន្និបាត មានភិក្ខុ ៧០ សែនរូប, ក្នុងតតិយសន្និបាត មានភិក្ខុ ៦០ សែនរូប ។

គ្រានោះពោធិសត្វនៃយើង ជាស្តេចទ្រង់រាជ្យព្រះនាមសុទស្សនៈ បានថ្វាយមហាទានមានចីវរទានជាដើម ដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបានចេញទ្រង់ព្រះផ្នួស ក្នុងសម្នាក់នៃព្រះបរមសាស្តា, ជាអ្នកប្រកបដោយគុណគឺអាចារៈ ព្រមទាំងមានបីតិរីករាយក្នុងពុទ្ធរតនៈជានិច្ច ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្យាករថា ភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងរវាង ៣១ កប្ប រាប់អំពីកប្បនេះទៅ ។ នគររបស់ព្រះពុទ្ធទ្រង់ព្រះនាមវេស្សភូនោះ ឈ្មោះអនោមៈ, ព្រះវរបិតាព្រះនាម

សុប្បតីតៈ, ព្រះវរពជមាតា ព្រះនាមយសវតី, ព្រះថេរៈឈ្មោះសោណៈ និងព្រះថេរៈឈ្មោះឧត្តរៈ ជាអគ្គសាវក, ព្រះថេរៈឈ្មោះឧបសន្តៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះកមា និងព្រះថេរីឈ្មោះសុមាលា ជាអគ្គសាវិកា, មានសាលព្រឹក្សជាពោធិ, មានព្រះកាយកម្ពស់ ៦០ ហត្ថ, មានព្រះជន្មាយុប្រមាណ ៦ ហ្មឺនឆ្នាំ ។

ចប់ វេស្សភូកថា ។

## ២២- កកុសន្ធវង្ស

ក្នុងកាលខាងក្រោយ នៃព្រះពុទ្ធទ្រង់ព្រះនាមវេស្សភូនោះបរិនិព្វានកន្លងទៅហើយ មានព្រះពុទ្ធ ៤ ព្រះអង្គគឺ ព្រះពុទ្ធព្រះនាមកកុសន្ធៈ១, ព្រះពុទ្ធព្រះនាមកោណាគមនៈ១, ព្រះពុទ្ធព្រះនាមកស្សបៈ១, ព្រះពុទ្ធជាបរមគ្រូនៃយើង១ កើតឡើងក្នុងភទ្ទកប្បនេះ ។ ព្រះពុទ្ធទ្រង់ព្រះនាមកកុសន្ធៈ មានសាវកសន្និបាតតែមួយដង ។ ក្នុងសាវកសន្និបាតនោះមានភិក្ខុចំនួន ៤ ហ្មឺនរូបប្រជុំគ្នា ។ គ្រានោះ ពោធិសត្វនៃយើង ជាស្ដេចទ្រង់ព្រះនាមខេមៈ ទ្រង់បានបរិច្ចាគមហាទាន ព្រមទាំងបាត្រ និងចីវរផង និងភេសជ្ជៈមានថ្នាំសម្រាប់បន្តក់ភ្នែកជាដើមផង ប្រគេនដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ហើយបានទ្រង់ព្រះសណ្ដាប់ឮព្រះធម្មទេសនានៃព្រះសាស្ដា មានសេចក្ដីនឿយណាយក្នុងកាម ហើយចេញ

ទ្រង់ព្រះផ្នួសក្នុងសម្នាក់នៃព្រះបរមគ្រូ ។ ទ្រង់ព្យាករថា ភិក្ខុនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គ ក្នុងអនាគត ។

នគររបស់ព្រះពុទ្ធទ្រង់ព្រះនាមកកុសន្ធៈនោះឈ្មោះខេមៈ, ព្រះពុទ្ធបិតា ជាព្រាហ្មណ៍នាមអគ្គិទត្ត, ព្រះពុទ្ធមាតា ជាព្រាហ្មណីនាមវិសាខា ព្រះថេរៈឈ្មោះវិធុរៈ និងព្រះថេរៈឈ្មោះសញ្ជីវៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះពុទ្ធិជៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះសាមា និងព្រះថេរីឈ្មោះចម្ពា ជាអគ្គសាវិកា, មានមហាសិរីសព្រឹក្ស (ដើមស្រេសយ៉ាងធំ) ជាពោធិ, មានព្រះកាយខ្ពស់ ៤០ ហត្ថ, មានព្រះជន្មាយុប្រមាណ ៤ ហ្មឺនឆ្នាំ ។

ចប់ កកុសន្ធកថា ។

## ២៣- កោនាគមនកថា

ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធ ទ្រង់ព្រះនាមកកុសន្ធៈនោះ បរិនិព្វានកន្លងទៅហើយ ទើបព្រះសាស្តាទ្រង់ព្រះនាម កោណាគមនៈ កើតឡើងក្នុងលោក ។ ព្រះមានព្រះភាគអង្គនោះ មានសាវកសន្និបាតតែមួយលើក, ក្នុងសាវកសន្និបាតនោះ មានភិក្ខុ ៤ ហ្មឺនរូប ។ គ្រានោះ ពោធិសត្វនៃយើង ជាស្តេចទ្រង់កផ្សព្រះនាមបព្វតៈ មានពួកអមាត្យចោមរោមជាបរិវារ ស្តេចយាងទៅកាន់សម្នាក់ នៃព្រះបរមសាស្តា,

បានទ្រង់ព្រះសំណាប់ព្រះធម្មទេសនា ហើយបានថ្វាយមហាទាន មានសំពត់កោសេយ្យ និងសំពត់កម្ពលជាដើម ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយចេញទ្រង់ព្រះផ្នួសក្នុងសម្នាក់នៃព្រះបរមសាស្តា ទ្រង់ព្យាករថា ភិក្ខុនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គ ក្នុងអនាគត ។

នគររបស់ព្រះពុទ្ធទ្រង់ព្រះនាមៈ កោណាគមនៈនោះ ឈ្មោះសោភវតី, ព្រះពុទ្ធបិតា ជាព្រាហ្មណ៍នាមយញ្ញទត្ត, ព្រះពុទ្ធមាតា ជាព្រាហ្មណីនាមឧត្តរា, ព្រះថេរៈឈ្មោះភិយ្យោសៈ និងព្រះថេរៈឈ្មោះឧត្តរៈ ជាអគ្គសាវ័ក, ព្រះថេរៈឈ្មោះសោត្ថិជៈ ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះសមុទ្ទា និងព្រះថេរីឈ្មោះឧត្តរា ជាអគ្គសាវិកា, មានឧទុម្ពរព្រឹក្ស (ដើមល្វា) ជាពោធិ, មានព្រះកាយកម្ពស់ ៦០ ហត្ថ, មានព្រះជន្មាយុប្រមាណ ៣ ហ្មឺនឆ្នាំ ។

ចប់ កោនាគមនកថា ។

---

## ២៤– កស្សបកថា

ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធព្រះនាមកោនាគមនៈនោះ ចូលនិព្វានកន្លងទៅហើយ ទើបព្រះសាស្តាទ្រង់ព្រះនាមកស្សបៈ កើតឡើងក្នុងលោក ។ ព្រះពុទ្ធអង្គនោះ មានសាវកសន្និបាតតែមួយដង, ក្នុង

សាវកសន្និបាតនោះ មានភិក្ខុចំនួន ២ ហ្មឺនរូប ។ គ្រានោះ ពោធិសត្វនៃយើង ជាមាណពឈ្មោះជោតិបាល ជាអ្នកចេះចាំត្រៃវេទ មានកិត្តិសព្ទល្បីខ្ចរខ្ចាយទៅក្នុងលោក ហើយជាមិត្រនឹងស្មូនឆ្នាំង ឈ្មោះឃដិការៈ ។ ថ្ងៃមួយ ជោតិបាលមាណពនោះ បានចូលទៅគាល់ព្រះសាស្តា ជាមួយនឹងឃដិការៈជាសំឡាញ់, បានស្តាប់ធម្មកថា ហើយចេញបួស ជាភិក្ខុក្នុងសម្នាក់ព្រះសាស្តា ជាភិក្ខុមានព្យាយាមដ៏មាំ រៀនព្រះត្រៃបិដកចេះចាំ, ជាអ្នកបរិបូណ៌ដោយវត្តប្រតិបត្តិដ៏ល្អក្នុងព្រះពុទ្ធសាសនា ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្យាករថា ភិក្ខុនេះ នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គ ក្នុងអនាគត ។

នគររបស់ព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈនោះ ឈ្មោះពារាណសី, ព្រះពុទ្ធបិតា ជាព្រាហ្មណ៍នាមព្រហ្មទត្ត, ព្រះពុទ្ធមាតា ជាព្រាហ្មណីនាមធនវតី, ព្រះថេរៈឈ្មោះតិស្សៈ និងព្រះថេរៈឈ្មោះភារទ្វាជៈ ជាអគ្គសាវក, ព្រះថេរៈឈ្មោះសព្វមិត្ត ជាពុទ្ធុបដ្ឋាក, ព្រះថេរីឈ្មោះអនុឡា និងព្រះថេរីឈ្មោះឧរុវេលា ជាអគ្គសាវិកា, មាននិគ្រោធព្រឹក្ស ( ដើមជ្រៃ ) ជាពោធិ, មានព្រះកាយកម្ពស់ ២០ ហត្ថ, មានព្រះជន្មាយុប្រមាណ ២ ហ្មឺនឆ្នាំ ។

ចប់ កស្សបកថា ។

# អង្គារភំ សត្ត ឧប្បត្តិកថា

តាមសេចក្ដីតំណាលថា ពោធិសត្វនៃយើង កាលដែលកំពុងស្វែងរកពោធិញ្ញាណ បានពុទ្ធព្យាករណ៍អំពីសម្នាក់ នៃព្រះពុទ្ធ ២៤ ព្រះអង្គ មានព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករ ជាដើម ។ ក្នុងវេលាកាលប៉ុណ្ណោះនេះ ពោធិសត្វព្យាយាមបំពេញបារមីតាំង ៣០ មានទានបារមីជាដើម និងមហាបរិច្ចាគ ៥ មានអង្គបរិច្ចាគជាដើម ដរាបដល់បានពុទ្ធព្យាករណ៍អំពីសម្នាក់នៃព្រះពុទ្ធព្រះនាមកស្សបៈ ជាទីបំផុត អស់កាលចំនួនបួនអសង្ខេយ្យនិងមួយសែនកប្ប ។

គ្រាដែលពោធិសត្វ កើតក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈនោះ បួសជាភិក្ខុឈ្មោះជោតិបាល បានស្ដាប់នូវពុទ្ធព្យាករណ៍ ហើយក៏ញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ទំប្រឹងបំពេញបារមីធម៌ ដោយវិរិយភាពដ៏មាំ ឥតមានសេចក្ដីធ្វេសប្រហែសឡើយ, លុះច្យុតចាកអត្តភាពនោះហើយ ក៏អន្ទោលទៅក្នុងភពតូចនិងភពធំ ដរាបដល់កើតជាវេស្សន្តរ សោយរាជ្យក្នុងជេតុត្តរ(១) ។ ព្រះបាទវេស្សន្តរនោះ ទ្រង់បរិច្ចាគនូវមហាទានដល់ស្មូមយាចក មានមនុស្សកំព្រាជាដើម ។ ដោយអំណាចតេជានុភាពនៃមហាទានរបស់ព្រះអង្គ អាចបណ្ដាលឲ្យមហាប្រឹថពី កក្រើក

១ នគរកបិលព័ស្តុ កាលណោះ ផ្លាស់នាមជា ជេតុត្តរ ។

ញាប់ញ័រ ហាក់ដូចជាបញ្ចេញសំឡេងថ្វាយពរសព្ទសាធុការ ចំពោះព្រះអគ្គី ១ ចេញទៅទ្រង់ព្រះផ្នួសជាឥសី គង់ក្នុងបណ្ណសាលា ទៀបភ្នំគិរីវង្គត, ព្រះអគ្គីបរិច្ចាគព្រះរាជបុត្រព្រះនាមជាលី និងព្រះរាជបុត្រីព្រះនាមកណ្ហា-ជិនា ព្រមទាំងអគ្គមហេសីព្រះនាមមទ្រី ដែលជាកំពូលនៃបារមី ដល់ព្រាហ្មណ៍ ទើបព្រះអគ្គីស្ដេចយាងត្រឡប់ មកគង់ក្នុងព្រះនគរជេតុត្តរវិញ ។ លុះអស់ព្រះជន្មាយុសោយព្រះទិវង្គតទៅ បានទៅកើតក្នុងតុសិត-បុរី ទ្រង់ព្រះនាមជា សន្តុសិតទេវបុត្រ សោយទិព្វសម្បត្តិឥស្សរិយយសដ៏ប្រសើរ អស់កាលកំណត់ ៤ ពាន់ ឆ្នាំទិព្វ (គឺ ៥៧កោដិ ៦ លាន ឆ្នាំមនុស្ស) ក្នុងឋានតុសិតទេវលោក ។

ចប់ អង្គាក់ សុត្ត ឧប្បត្តិកថា ។

ចប់ ពុទ្ធប្បវត្តិ ឬបេមិកាខ ភាគ ១ ។

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ សយ សិលា

វិច្ឆិកា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ុ ដារា និងលោកស្រី សុន ដាវី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ឺស និងលោកម្តាយ ឌិន សៅខុន

សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

## មានលក់ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគាររ័ត្នរតន៍"

# 136E0 វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ **012 706 581**

**097 905 00 55**

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។